សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

## របាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សា

# ការចុះបញ្ជីកម្មសិទ្ធិបញ្ញា នៅកម្ពុជា

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **លាម លិះ**

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **ហាប់ ផល្លី**

ថ្នាក់ **បរិញ្ញាបត្រជាន់ខ្ពស់ នីតិសាស្ត្រ**

ជំនាញ **នីតិឯកជន** ជំនាន់១០

ឆ្នាំចូលសិក្សា ២០១៣

ឆ្នាំសរសេររបាយការណ៍ ២០១៤

**រក្សាសិទ្ធិដោយ** Khmer Famous

# អារម្ភកថា

ក្នុងបរិបទដែលកម្ពុជាបានចូលខ្លួនយ៉ាងជ្រៅក្នុងចរន្តនៃសេដ្ឋកិច្ចទីផ្សាសេរីយើងមានការលំបាកជាច្រើនប៉ុន្តែទន្ទឹមនិងការលំបាកនេះយើងក៏ត្រូវដោះស្រាយនូវបញ្ហាអ្វីដែលជាអទិភាពដំបូងបំផុតសំរាប់ប្រទេសជាតិដែរ។ ទាំងវិធានគតិយុត្តិទាំងនីតិវិធីសំរាប់ដំណើរការសកម្មភាពស្ថាប័នដើម្បីបំរើឲ្យការងារសេដ្ឋកិច្ចជាតិក្នុងបរិបទថ្មីនេះ សុទ្ធតែជាតំរូវការមិនអាចខ្វះបានទាំងអស់ ប៉ុន្តែក្នុងបរិបទសាកលភាវូពាណិជ្ជកម្ម ជាបំបូងយើងត្រូវដឹងថា កម្មសិទ្ធិឯកជនជាវិញ្ញាសារមួយដែលមិនអាចខ្វះបាន។ កង្វះចំណេះដឹងអំពីរបបគតិយុត្តិគ្រប់គ្រងកម្មសិទ្ធិជាមូលហេតុមួយក្នុងចំណោមមូលហេតុនានានៃជម្លោះកម្ពុជាបច្ចុប្បន្ន។ ចំពោះមុខនេះយើងជ្រើសយកកម្មសិទ្ធិបញ្ញាមកចាត់ទុកថាចាំបាច់ ដើម្បីចូលរួមចំនែកក្នុងការជម្រុញកម្ពុជាអោយទាន់ចរន្ត ប្រវត្តសាស្រ្តសកលលោកនឹងគេ។ យោងតាមតម្រូវការ ចាំបាច់ នៃការយល់ដឹងពីញ្ញានេះទើបខ្ញុំបាទសម្រេចយក "ការចុះបញ្ជីកម្មសិទ្ធិបញ្ញានៅកម្ពុជា" មកបកស្រាយបំភ្លឺតាមរយះការរៀបចំចងក្រងជារបាយការណ៍បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ក្នុងគោលបំណងបង្កឲ្យមានភាពងាយស្រួលក្នុងការយល់ដឹង អំពីនីតិវិធីប្រធានបទនេះមានគោលដៅចូលរួម បំពេញកង្វះខាតនូវឯសារការស្រាវជ្រាវនិង ផ្តល់ចំណេះដឹងដល់អ្នកសិក្សារួមទាំង បណ្តារប្រជារាស្រ្តខ្មែរដើម្បីទទួលបានបន្ថែមទៀត នូវចំណេះដឹងជាសាកលនិងជាក់លាក់មួយក្នុងការបំពេញភាកិច្ចរបស់កម្ពុជា ។ ប្រធានបទស្តីពី "ការចុះបញ្ជីកម្មសិទ្ធិបញ្ញានៅកម្ពុជា" នេះជារបាយការណ៍ថ្មី មួយក្នុងចំណោមរបាយការណ៍បញ្ចប់ការសិក្សារបស់ និស្សិតនីតិសាស្រ្ត គ្រប់ជុំនាន់កន្លងមក ។ ហើយខ្ញុំបាទជឿជាក់ថារបាយការណ៍នេះពុំមាន ភាពល្អឥតខ្ចោះនោះទេ ដូចច្នេះហើយមាន ភាពខ្វះចន្លោះជាច្រើនទៅលើផ្នែកអត្ថន័យ ការរៀបរៀងកំហុសឆ្គងផ្នែកវាស័ព្ទអក្ខរាវិរុទ្ធ និងវេយ្យាករណ៍តែងតែកើតមានមិនអាច ជៀសវាងបាន។ ខ្ញុំបាទរងចាំជានិច្ចនូវមតិរិះគន់ស្ថាពនានិងការណែនាំពីមិត្តអ្នកអានដោយកក្តីសោមនស្សរីករាយជានិច្ច។

# **សេចក្តីថ្លែងអំណរគុណ**

ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ **លោកឪពុក អ្នកម្តាយ** ដែលអ្នកមានគុណទាំងពីរបានផ្តល់កំណើត និងបានចិញ្ចឹមបីបាច់ថែរក្សា ផ្តល់ដំបូន្មានល្អៗ ព្រមទាំងលះបង់ស្មារតីទាំងផ្លូវកាយទាំងផ្លូវចិត្ត ក៏ដូចជាការផ្តល់នូវការទំនុកបម្រុងគ្រប់បែបយ៉ាងដល់ខ្ញុំបាទ ដើម្បីទទួលបាននូវចំណេះដឹងរហូតដល់ពេលបច្ចុប្បន្ននេះ ។

សូមថ្លែងអំណរគុណយ៉ាងជ្រៀលជ្រៅនិងដោយក្តីស្មោះត្រង់ជាទីបំផុតដល់លោកសាស្ត្រាចារ្យ **ហាប់ ផល្លី** សាស្ត្រាចារ្យសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រ សេដ្ឋកិច្ច ដែលបានយកចិត្តទុកដាក់ បង្ហាត់បង្រៀនខ្ញុំបាទ និងព្រមទាំងបានផ្តល់ជា ប្រធានបទក្នុងការស្រាវជ្រាវមួយនេះ ។

សូមថ្លែងអំណរគុណចំពោះ **លោកនាយក នាយករង លោកព្រឹទ្ធបុរសរង** ព្រមទាំង**លោកសាស្ត្រាចារ្យទាំងអស់** របស់មហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រ សេដ្ឋកិច្ច ដែលបានខិតខំបណ្តុះបណ្តាលយើងខ្ញុំយ៉ាងយកចិត្តទុកដាក់ស្របនឹងគោលនយោបាយ របស់រាជរដ្ឋាភិបាលក្នុងការពង្រឹងធនធានមនុស្ស នៅក្នុងព្រះរាជាណាចក្រកម្ពុជានេះ។

សូមថ្លែងអំណរគុណចំពោះ**លោកគ្រូ វ៉ា រ៉ុតសាន** ប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញាដែលបានបង្ហាត់បង្រៀនខ្ញុំបាទនៅ ក្រសួងពាណិជ្ជកម្ម ហើយក៏សូមអរគុណទៅដល់លោកគ្រូ អ្នកគ្រូ ដែលបានបង្រៀនខ្ញុំបាទផ្នែកភ្នាក់ងារតំណាងនៃម្ចាស់ម៉ាកស្របច្បាប់ជំនាន់ពីរផងដែរ ។

ជាទីបញ្ចប់នេះ ខ្ញុំបាទសូមប្រសិទ្ធិពរជ័យ ជូនដល់លោកអ្នកមានគុណទាំងអស់ សូមឲ្យជួបតែសេចក្តីសុខចម្រើន អាយុយឺនយូរ សម្រេចបានជោគជ័យគ្រប់ភារកិច្ច និង ប្រកបដោយសិរីសួស្តី ជ័យមង្គល សុខភាពល្អ គ្រប់ពេលវេលាកុំបីខាន ។

# **សេចក្ដីធានាអះអាង**

ខ្ញុំបាទឈ្មោះ **លាម លិះ** អក្សឡាតាំង LEAM LIS ភេទ ប្រុស កើតថ្ងៃទី ០១ ខែ តុលា ឆ្នាំ ១៩៩០ នៅភូមិសណ្ដាន់ សង្កាត់ទឹកវិល ក្រុងសៀមរាប ខេត្ត សៀមរាប។ ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ នីតិសាស្ត្រ ជំនាញនីតិឯកជន ជំនាន់ទី១០ ជំហាន២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច រាជធានីភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា សូមធ្វើការអះអាង និងទទួលខុសត្រូវទាំងស្រុងលើ ខ្លឹមសារនៃឯកសារនេះ ដែលពិតជាស្នាដៃនៃការសិក្សាស្រាវជ្រាវរបស់ខ្ញុំបាទពិត ប្រាកដមែន។

រាជធានីភ្នំពេញថ្ងៃទី............ខែ.................ឆ្នាំ២០១២

ហត្ថលេខា

**លាម លិះ**

# មាតិកា


**អារម្ភកថា**..................................................................................................................................... i

**សេចក្តីថ្លែងអំណរគុណ** ............................................................................................................ii

**សេចក្តីធានាអះអាង** ...................................................................................................................vi

**អក្សរកាត់** .......................................................................vError ! Bookmark not defined.

**សេចក្តីផ្តើម**.................................................................................................................................... 1

**ជំពូកទី១** : **សញ្ញាណទូទៅនៃកម្មសិទ្ធិបញ្ញានៅកម្ពុជា**........................................................... 2

១.១. ស្ថាប័នកម្មសិទ្ធិបញ្ញា ................................................................................................ 2

១.១.១. ស្ថាប័នអន្តរជាតិ............................................................................................ 2

១.១.២. ស្ថាប័នជាតិ ................................................................................................... 3

១.១.៣. ស្ថាប័នដែលមានសមត្ថកិច្ចកម្មសិទ្ធិបញ្ញា........................................................ 4

១.២. ទំរង់នៃការការពារកម្មសិទ្ធិបញ្ញានៅកម្ពុជា .................................................................. 5

១.២.១. កម្មសិទ្ធិឧស្សាហកម្ម..................................................................................... 6

១.២.២. កម្មសិទ្ធិអក្សរសាស្រ្ត និងសិល្បៈ....................................................................... 7

១.៣. តារាងរយៈពេលនៃការការពារកម្មសិទ្ធិបញ្ញា.................................................................. 8

**ជំពូកទី២ នីតិវិធីនៃការចុះបញ្ជីកម្មសិទ្ធិបញ្ញា**.............................................................. 10

២.១. ការចុះបញ្ជីម៉ាក.......................................................................................................... 10

២.១.១. ដំណាក់កាលនៃការដាក់ពាក្យនិងទទួលស្គាល់ការដាក់ពាក្យ ............................. 11

២.១.៣. ដំណាក់កាលនៃការចុះបញ្ជី និងធ្វើការបោះផ្សាយ ........................................... 12

២.១.៤ ដំណាក់កាលនៃការប្ដឹងតវ៉ា ការប្ដឹងជំទាស់ និងសវនាការ ..................................... 12

២.២. ប្រកាសនីយបត្រតក្កកម្ម ឬវិញ្ញាបនប័ត្រម៉ូដែលមានអត្ថប្រយោជន៍ ........................... 13

២.៣. សិទ្ធិអ្នកនិពន្ធ ........................................................................................ 14

**ជំពូកទី៣ អត្ថប្រយោជន៍នៃការចុះបញ្ជីកម្មសិទ្ធិបញ្ញា** ................................................. 16

៣.១. អត្ថប្រយោជន៍ចំពោះសង្គម ...................................................................... 16

៣.២. អត្ថប្រយោជន៍ចំពោះបុគ្គល ...................................................................... 18

៣.៣. អត្ថប្រយោជន៍ពីការចុះបញ្ជី ..................................................................... 19

**សេចក្ដីសន្និដ្ឋាន** ................................................................................................ 21

**អនុសាសន៍** ........................................................................................................ 22

**ឧបសម្ព័ន្ធ** ........................................................................................................ 25

# អក្សរកាត់

WTO = World Trade Organisations.

TRIPS = Related Aspects of Intellectual Property Right.

WIPO = World Intellectual Property Organization.

GIs = Geographical Indications.

IPAS = Intellectual Property Administration System.

# សេចក្តីផ្តើម

កំណើនសេដ្ឋកិច្ចដែលរួមចំណែកដោយចំណេះដឹង កម្មសិទ្ធិបញ្ញា គឺជាការពិចារណាដ៏សំខាន់ក្នុងការសម្រេចចិត្តផ្នែកពាណិជ្ជកម្ម។ ប្រទេសកម្ពុជាមានច្បាប់ទូលាយដើម្បីការពារកម្មសិទ្ធិបញ្ញាដែលស្របទៅនឹងអនុសញ្ញាអន្តជាតិសំខាន់ៗស្តីពីកម្មសិទ្ធិបញ្ញា។ កិច្ចការពារកម្មសិទ្ធិបញ្ញាសមស្របរបស់ក្រុមហ៊ុនជាជំហានដ៏សំខាន់ក្នុងការ កំណត់អំពីការរំលោភបំពាន និងការប្រែក្លាយគំនិតទៅជាទ្រព្យអាជីវកម្ម ដែលមានតម្លៃ។ ការទាញយកផលប្រយោជន៍ពេញលេញ ពីប្រព័ន្ធការពារកម្មសិទ្ធិបញ្ញា អាចធ្វើឱ្យក្រុមហ៊ុន ទទួលបានចំណូលពីការបង្កើតថ្មី និងការច្នៃប្រឌិតរបស់ខ្លួនដែលជាការលើកទឹកចិត្តនិងបង្កើនមូលធនដល់ការស្រាវជ្រាវនិងការអភិវឌ្ឍន៍។ មានផលិតផលឬសេវាថ្មីៗជាច្រើន ដែលការពារក្រោមប្រភេទផ្សេងៗគ្នានៃកម្មសិទ្ធិបញ្ញា។

កម្មសិទ្ធិបញ្ញាដែលជាលក្ខណៈដើមរបស់ខ្លួនចាំបាច់ត្រូវចុះបញ្ជីក្នុងប្រទេស ដែលគេចង់ការពារ។ ច្បាប់បរទេសអាចអនុវត្តបានប្រសិនបើមានការដាក់ពាក្យសុំសិទ្ធិលើកម្មសិទ្ធិបញ្ញា ក្នុងប្រទេសនោះ។ ដើម្បីទទួលបាននូវការការពារនៅក្រៅប្រទេសកម្ពុជាចាំបាច់ត្រូវតែដាក់ពាក្យសុំនៅប្រទេសដែលខ្លួនចង់ការពារនោះដោយផ្ទាល់ ឬចំពោះកម្មសិទ្ធិបញ្ញាមួយចំនួនអាចធ្វើឡើងតាមប្រព័ន្ធអន្តរជាតិដែលកម្ពុជានិងចាប់ផ្តើមអនុវត្តនៅពេលដ៏ខ្លីខាងមុខ។

ការចុះបញ្ជីកម្មសិទ្ធិបញ្ញាជាកត្តាមួយដែលមានសារៈសំខាន់ចាំ បាច់បំផុតសំរាប់ប្រទេសជាតិ និងសំរាប់សហគ្រាសដូចជា បង្កើតអត្តសញ្ញាណសហគ្រាសតាមរយៈកាចុះបញ្ជីម៉ាក បង្ការគូប្រកួតប្រជែងពីការចម្លង ឬធ្វើត្រាប់តាមផលិតផលរបស់ខ្លួន រក្សានៅស្នាដៃដែលជាស្នាដៃតំណាងតំបន់ឬផលិតផលដែលជាមុខមាត់ប្រទេសជាតិនិងមិនអោយមានការប្រកួតប្រជេងមិនស្មោះត្រង់។

ទាំងនេះគឺជាផលប្រយោជន៍នៃសិទ្ធិបញ្ញា ដែលមានប្រភពពីការចុះបញ្ជីត្រឹមត្រូវនិងការគោរពច្បាប់និងបទបញ្ញត្តិនានាស្តីពីកម្មសិទ្ធិឯកជន។ តើអ្វីទៅជាកម្មសិទ្ធិបញ្ញា? តើការចុះបញ្ជីកម្មសិទ្ធិបញ្ញានៅកម្ពុជាប្រព្រឹត្តទៅយ៉ាងដូចម្តេច? តើស្ថាប័នណាខ្លះជាកន្លែងដែលមានសមត្ថកិច្ចក្នុងការចុះបញ្ជីកម្មសិទ្ធិបញ្ញានៅកម្ពុជា? តើសព្វថ្ងៃនេះកម្ពុជាទទួលបានការចុះបញ្ជីប៉ុន្មានមុខហើយអ្វីខ្លះ?

# ជំពូកទី១ : សញ្ញាណទូទៅនៃកម្មសិទ្ធិបញ្ញានៅកម្ពុជា

កម្មសិទ្ធិរបស់មនុស្សគ្រប់រូបមានបីយ៉ាងគឺ កម្មសិទ្ធិលើអចលនវត្ថុ កម្មសិទ្ធិលើចលនវត្ថុ និង កម្មសិទ្ធិបញ្ញា។ កាលដើមឡើយ ការការពារកំណត់សំខាន់តែលើកម្មសិទ្ធិជាចលនទ្រព្យ និង អចលនទ្រព្យតែប៉ុណ្ណោះ រដ្ឋមិនបានយកចិត្តទុកដាក់ដល់ការការពារលើផ្នែកកម្មសិទ្ធិបញ្ញាឡើយ។ ប៉ុន្តែសង្គមដែលគិតគូរការពាររបៀបនេះ នាំអោយបាត់បង់នូវការលើកទឹកចិត្តក្នុងការបង្កើតថ្មី និង អាចធ្វើអោយ សង្គមនោះមានភាពយឺតយ៉ាវក្នុងការអភិវឌ្ឍ ព្រោះថាទាំងចលនទ្រព្យនិងអចលន ទ្រព្យសុទ្ធសឹងតែកើតឡើងពីបញ្ញាទាំងអស់។ កម្មសិទ្ធិបញ្ញាជាកម្មសិទ្ធិមួយដែលមានភាពអរូបីយ៍ និងជាកម្មសិទ្ធិដែលបុគ្គលគ្រប់រូបមានលើការច្នៃប្រឌិត ការបង្កើតថ្មី លើស្នាដៃនានា របស់ខ្លួន ទាំង ស្នាដៃផ្នែកអក្សរសាស្ត្រ សិប្បកម្ម និម្មិតសញ្ញា ឈ្មោះក្នុងពាណិជ្ជកម្ម -ល-។[1]

## ១.១. ស្ថាប័នកម្មសិទ្ធិបញ្ញា

កម្មសិទ្ធិបញ្ញាពុំមែនស្ថិតនៅក្នុងក្របខ័ណ្ឌប្រទេសតែមួយប៉ុណ្ណោះទេប៉ុន្តែវាត្រូវបានសាយភាយ យ៉ាងទូលាយក្នុងក្របខណ្ឌសកលជាអន្តរជាតិដូចនេះស្ថាប័នដែលពាក់ព័ន្ធត្រូវតែមានស្ថាប័នជាតិ និងអន្តរជាតិ។

### ១.១.១. ស្ថាប័នអន្តរជាតិ

ទាក់ទងនិងកម្មសិទ្ធិបញ្ញាកម្ពុជាបានសហការជាមួយបណ្តាប្រទេសផ្សេងៗទៀត ក៏ដូចជាអង្គ ការអន្តជាតិដើម្បីការពារការវិនិយោគ និងវិស័យកម្មសិទ្ធិបញ្ញា។ ស្ថាប័នអន្តជាតិដែលមានការ ទាក់ទងនិងវិស័យពាណិជ្ជកម្មក៏ដូចជាវិស័យកម្មសិទ្ធិបញ្ញា មានអង្គការពាណិជ្ជកម្មពិភពលោក ដែលជាអង្គការអន្តរជាតិតែមួយគត់ដែលចាត់ចែងទាក់ទងនឹងបទបញ្ញត្តិសកលស្តីពី ពាណិជ្ជកម្ម រវាងប្រទេសទាំងឡាយដែលជាសមាជិករបស់ខ្លួន។ ក្នុងក្របខណ្ឌអង្គការពាណិជ្ជកម្មពិភពលោក ប្រទេសកម្ពុជាបានចូលរួមក្នុងកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្ម ពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា (TRIPS) ដែលជាកិច្ចព្រមព្រៀងមានគោលដៅការពារកម្មសិទ្ធិបញ្ញា នៅក្នុងបណ្តារប្រទេស សមាជិក WTO។ [2] ក្រៅពីសមាជិកភាពក្នុងអង្គការពាណិជ្ជពិភពលោកកម្ពុជាក៏បានចូលជា សមាជិកភាពរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក ដែលមានឈ្មោះកាត់ថា WIPO ។

---

[1] ក្រសួងពាណិជ្ជកម្ម និងធនាគារអភិវឌ្ឍន៍អាស៊ី, សៀវភៅណែនាំសម្រាប់ចុះបញ្ជីពាណិជ្ជកម្ម និងប្រកបអាជីវកម្ម អនុឡោមតាមច្បាប់, អាចរកបាននៅ http://kh-cheyrithy.blogspot.com/p/blog-page_03.html ។

[2] http://www.wipo.int/treaties/en/text.jsp?file_id=305907 (ចូលទស្សនាថ្ងៃទី ១៩ ធ្នូ ២០១៤)។

WIPO គឺជាអង្គការអន្តរជាតិដែលសំរបសំរួលកិច្ចការអនុវត្ត និងកិច្ចការគតិយុត្តិដល់ប្រទេសជាសមាជិករបស់ខ្លួនក្នុងក្របខណ្ឌនៃកិច្ចព្រមព្រៀង ស្តីពីកម្មសិទ្ធិបញ្ញា។[3] WIPO គ្រប់គ្រងរាល់កិច្ចព្រមព្រៀង និងសន្ធិសញ្ញា២៦ ដែលស្តីពីកម្មសិទ្ធិបញ្ញា។[4] ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នដើម្បីក្លាយជាសមាជិកនៃអនុសញ្ញាទីក្រុងប៉ារីសស្តីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម។ កិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការការពារពាណិជ្ជកម្ម និងកម្មសិទ្ធិបញ្ញាទៅវិញទៅមករវាង កម្ពុជា និងសហរដ្ឋអាមេរិច កិច្ចព្រមព្រៀង ស្តីពីកិច្ចសហប្រតិបត្តិការការពារពាណិជ្ជកម្ម និងកម្មសិទ្ធិបញ្ញាទៅវិញទៅមករវាង កម្ពុជា និងប្រទេសថៃ កិច្ចព្រមព្រៀង រវាងកម្ពុជា និងប្រទេសចិន ។ ការចុះកិច្ចព្រមព្រៀងជាមួយបណ្តាប្រទេសផ្សេង ក៏ដូចជាក្លាយជាសមាជិកភាពនៃអង្គការអន្តជាតិធ្វើអោយស្នាដៃលើការបង្កើតរបស់កូនខ្មែរបានទទួលស្គាល់សកលលោក និងទាក់ទាញដល់អ្នកវិនិយោគដើម្បីមកធ្វើការសិក្សាពីសក្តានុពលសេដ្ឋកិច្ចកម្ពុជា។

### ១.១.២. ស្ថាប័នជាតិ

ជំនួយរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោកមកកម្ពុជាគឺធ្វើយ៉ាងណាឲ្យប្រព័ន្ធគ្រប់គ្រង ឬស្ថាប័នជាតិខាងកម្មសិទ្ធិបញ្ញាកម្ពុជាមានភាពទំនើប។ យោងតាមការសន្យារបស់កម្ពុជានៅក្នុងការចូលជាសមាជិក WTO ក្នុងឋានៈជាប្រទេសកំពុងអភិវឌ្ឍ កម្ពុជាត្រូវបានអនុគ្រោះដល់ឆ្នាំ២០០៨ ក្នុងការតាក់តែងច្បាប់ និងបទដ្ឋានគតិយុត្តិពាក់ព័ន្ធ ដើម្បីការពារកម្មសិទ្ធិបញ្ញាក្នុងទឹកដីរបស់ខ្លួនប្រកបដោយប្រសិទ្ធិភាព។ ប៉ុន្តែដោយសារកង្វះខាតធនធានមនុស្សបច្ចេកទេសនិងការយល់ដឹងផ្នែកកម្មសិទ្ធិបញ្ញាប្រទេសកម្ពុជាបានពន្យាពេលនៃការសន្យារបស់ខ្លួនរហូតដល់២០១៨។ យោងតាមបញ្ហាដែលបានលើកឡើងខាងលើ វាមានសារៈសំខាន់ក្នុងការសិក្សាអំពីប្រវត្តិនៃការគ្រប់គ្រងកម្មសិទ្ធិបញ្ញារបស់កម្ពុជា ដោយយើងសិក្សាលើស្ថាប័នអាជ្ញាធរគ្រប់គ្រងកម្មសិទ្ធិបញ្ញា អាជ្ញាធរអនុវត្តកម្មសិទ្ធិបញ្ញា និងដំណោះស្រាយវិវាទ និងអំពើរំលោភកម្មសិទ្ធិបញ្ញា។ អាជ្ញាធររដ្ឋបាលគ្រប់គ្រងកម្មសិទ្ធិបញ្ញានៅប្រទេសកម្ពុជា មានការវិវឌ្ឍន៍ជាច្រើនដំណាក់ ដែលមានដូចខាងក្រោម

នៅប្រទេសកម្ពុជាវិស័យកម្មសិទ្ធិបញ្ញាត្រូវបានដាក់នៅក្រោមការគ្រប់គ្រងរបស់ក្រសួងបីផ្សេងៗគ្នាគឺ ក្រសួងពាណិជ្ជកម្ម(គ្រប់គ្រងវិស័យម៉ាក ពាណិជ្ជនាម) ក្រសួងឧស្សាហកម្មរ៉ែនិងថាមពល(គ្រប់គ្រងវិស័យប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ គំនូរឧស្សាហកម្ម) និងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ(គ្រប់គ្រងវិស័យសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់

[3] http://www.wipo.int/about-wipo/en/ (ចូលទស្សនាថ្ងៃទី ១៩ ធ្នូ ២០១៨)។

[4] http://www.wipo.int/treaties/en/ (ចូលទស្សនាថ្ងៃទី ១៩ ធ្នូ ២០១៨)។

ប្រហែល)។[5] ក្នុងដំណាក់កាលនៃការរៀបចំដំណើរការនៃគណៈកម្មការជាតិ វិស័យកម្មសិទ្ធិបញ្ញាស្ថិតនៅក្រោមការគ្រប់គ្រងរបស់ស្ថាប័នបីផ្សេងគ្នា ដែលការបែងចែកសមត្ថកិច្ចធ្វើអោយដំណើរការក្នុងការគ្រប់គ្រង់មានភាពយឺតយ៉ាវដោយតម្រូវឲ្យឆ្លងកាត់ថ្នាក់ដឹកនាំច្រើន។

### ១.១.៣. ស្ថាប័នដែលមានសមត្ថកិច្ចកម្មសិទ្ធិបញ្ញា

ករណីមានបទល្មើសកម្មសិទ្ធិបញ្ញាកើតឡើង ម្ចាស់សិទ្ធិអាចចាត់វិធានការសមស្របតាមផ្លូវច្បាប់ប្រឆាំងនឹងអំពើរំលោភសិទ្ធិ នៅចំពោះមុខស្ថាប័នមានសមត្ថកិច្ច អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ អាហរ័ណ និងបង្រ្កាបការក្លែងបន្លំ (កាំកុងត្រូល[6]) សមត្ថកិច្ចនៃការគ្រប់គ្រង និងការបង្រ្កាបបទល្មើសទាក់ទងនិងគុណភាពសុវត្ថិភាពទំនិញនិង សេវា ។[7] ក្នុងចំណោមសមត្ថកិច្ចខាងលើកាំកុងត្រូលក៏មានសមត្ថកិច្ចក្នុងការបង្រ្កាបការក្លែងបន្លំផលិតផលដែលប៉ះពាល់ដល់សុខភាពអ្នកប្រើប្រាស់ និងអ្នករំលោភកម្មសិទ្ធិបញ្ញាផងដែរ។ កាំកុងត្រូលត្រូវសហការជាមួយអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ដោយផ្សែ្រកលើកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ។ សម្ថកិច្ចរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករទាក់ទងនិងការការពារកម្មសិទ្ធិបញ្ញាត្រូវបានវិធានការតាមមាត់ច្រកព្រំដែនបើសង្ស័យថាទំនិញក្លែងបន្លំម៉ាកនោះគយមានសិទ្ធិឃាត់ទុក។ ក្នុងករណីនេះអាជ្ញា ធរគយ និងរដ្ឋាករនៅតាមមាត់ច្រកព្រំដែនមានសមត្ថកិច្ចឃាត់ ឬព្យួរទុកទំនិញដែលជាប់សង្ស័យជាមួយអំពើរំលោភម៉ាក ដោយផ្អែកតាមបណ្ដឹងរបស់ម្ចាស់ម៉ាក។ ម្ចាស់ម៉ាកអាចធ្វើពាក្យបណ្ដឹងទៅរដ្ឋបាលគយ ឬអាជ្ញាធរមានសមត្ថកិច្ច ឬតុលាការដើម្បីព្យួរទុកនូវការធ្វើបែងបទ ទំនិញណាដែលសង្ស័យថាមានកាក្លែងក្លាយ។[8]

ការិយាល័យប្រឆាំងបទល្មើសសេដ្ឋកិច្ចនៃក្រសួងមហាផ្ទៃ ត្រូវបានបង្កើតឡើងដែលមានគោលដៅប្រឆាំងបង្រ្កាបបទល្មើសកម្មសិទ្ធិបញ្ញា ឬផលិតផលក្លែងបន្លំនៅលើទីផ្សារនៃប្រទេស កម្ពុជា ការិយាល័យប្រឆាំងបទល្មើសសេដ្ឋកិច្ចលាតសន្ធឹងទូទាំងប្រទេស។ ក្រោយការបង្រ្កាប និងរិបអូសវត្ថុតាងនៃបទល្មើស នគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ចត្រូវកសាងសំណុំរឿងបញ្ជូនទៅតុលាការដើម្បីចាត់នីតិវិធីតាមច្បាប់។ តាមរយៈបណ្ដឹងរបស់ម្ចាស់សិទ្ធិ និងក្រោមការដឹកនាំរបស់ព្រះរាជ

[5] សេចក្ដីសម្រេចស្ដីពីការបង្កើតគណៈកម្មការគ្រប់គ្រងផ្នែកទាំងបីនៃកម្មសិទ្ធិបញ្ញា, លេខ១៦សសរ, ២២ កុម្ភ: ១៩៩៩។
[6] អនុក្រឹត្យស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម, លេខ៩១អនក្រ/បក,០១ សីហា ១៩៩៧។
[7] ច្បាប់ស្ដីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព នៃផលិតផលទំនិញ និងសេវា, លេខសន/រកម/០៦០០/០០១,២៦ មិថុនា ២០០០, ជំពូក ៦។
[8] ច្បាប់ស្ដីពីម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជេញមិនស្មោះត្រង់, លេខ សន/រកម/០២០២/០០៦, ០៧ កុម្ភ: ២០០២, មាត្រា៣៥។

អាជ្ញារការិយាល័យនគបាល សេដ្ឋកិច្ចខេត្ត - ក្រុងមានសមត្ថកិច្ចចុះបង្ក្រាបទល្មើសដែលកើតមានឡើងក្នុងដែនដីរដ្ឋបាលក្រោមការគ្រប់គ្រងរបស់ខ្លួន។ ដូចគ្នានេះដែរក្រោយពីការបង្ក្រាបនិងរឹបអូសវត្ថុតាងនៃបទល្មើស នគបាលសេដ្ឋកិច្ចត្រូវកសាងសំណុំរឿងបញ្ជូនទៅតុលាការដើម្បីចាត់នីតិវិធីតាមច្បាប់។[9]

ប្រទេសកម្ពុជាពុំទាន់មានតុលាការពិសេសពាណិជ្ជកម្ម ឬកម្មសិទ្ធិបញ្ញាដាច់ឡែកនៅឡើយទេ។ មិនខុសពីវិស័យច្បាប់ពិសេសផ្សេងៗទៀតដែរ ក្នុងករណីវិវាទលើវិស័យម៉ាក តុលាការនៃនីតិរួមមានសមត្ថកិច្ច។ តុលាការកម្ពុជាមានសមត្ថកិច្ចទៅលើរឿងក្តីទាំងអស់រួមទាំងរឿងក្តីរដ្ឋបាលផងដែរ នៅក្នុងន័យនេះតុលាការនៃនីតិរួមមានសមត្ថកិច្ចក្នុងការជំនុំជំរះលើបណ្តឹងពាក់ព័ន្ធនិងវិស័យកម្មសិទ្ធិបញ្ញាដោយផ្អែកលើច្បាប់និងបទបញ្ញត្តិជាធរមាននៃផ្នែកនីមួយៗ។[10]

## ១.២. ទំរង់នៃការការពារកម្មសិទ្ធិបញ្ញានៅកម្ពុជា

សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ កម្មសិទ្ធិបញ្ញា ជាឧបករណ៍មួយយ៉ាងសំខាន់សម្រាប់ពង្រីកវិស័យពាណិជ្ជកម្ម និងទាក់ទាញការវិនិយោគជាតិ និងអន្តរជាតិ។ ប៉ុន្តែសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ទាំងនោះ ហាក់បីដូចជាពុំទាន់យល់អំពីអត្ថប្រយោជន៍កម្មសិទ្ធិនៅឡើយទេ។

កម្មសិទ្ធិបញ្ញាត្រូវបានបែងចែកជាពីរប្រភេទគឺកម្មសិទ្ធិឧស្សាហកម្ម សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល។ កម្មសិទ្ធិឧស្សាហកម្មរួមមាន ប្រកាសនីយបត្រតក្កកម្ម ម៉ាក គំនូរឧស្សាហកម្ម និងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ។ ចំណែកឯសិទ្ធិអ្នកនិពន្ធ រួមមានស្នាដៃអក្សរសាស្ត្រ និងសិល្បៈទាំងឡាយដូចជារឿងប្រលោមលោក កំណាព្យ និងល្ខោន ភាពយន្ត ស្នាដៃតន្ត្រី គំនូរ រូបថត ចម្លាក់ និងស្ថាបត្យកម្មជាដើម។ សិទ្ធិប្រហាក់ប្រហែល គឺសំដៅទៅលើសិទ្ធិរបស់អ្នកសម្តែង ផលិតករហ្វូណូក្រាម និងអង្គភាពទូរផ្សាយ។

ផលប្រយោជន៍ពីកិច្ចការពារនៃម្ចាស់កម្មសិទ្ធិអាចបង្ហាញឲ្យឃើញថាអ្នកបង្កើតស្នាដៃកម្មសិទ្ធិបញ្ញាអាចទទួលបានថវិកាត្រលប់មកវិញតាមរយៈសិទ្ធិរបស់គាត់ក្រោយពីការចុះបញ្ជីដោយកិច្ចសន្យាពាណិជ្ជកម្ម ព្រមទាំងការលក់អាជ្ញាប័ណ្ណ។

---

[9] ច្បាប់ស្តីពីម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជេញមិនស្មោះត្រង់, លេខ សន/រកម/០២០២/០០៦, ០៧ កុម្ភៈ ២០០២, មាត្រា ៩១។

[10] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២១ កញ្ញា ១៩៩៣, មាត្រា១០៩។

### ១.២.១. កម្មសិទ្ធិឧស្សាហកម្ម

កម្មសិទ្ធិឧស្សាហកម្មសំដៅដល់ផលិតផលដែលស្ថិតនៅក្នុងវិស័យឧស្សាហកម្មទាំងឡាយ រួមទាំងវិស័យវាយនភណ្ឌផងដែរ។ កម្មសិទ្ធិបញ្ញានៅក្នុងកម្មសិទ្ធិឧស្សាហកម្មរួមមាន ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ គំនូរឧស្សាហកម្ម ម៉ាក ការសម្ងាត់ពាណិជ្ជកម្ម ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ។

ក្នុងប្រទេសកម្ពុជាគំនូរឧស្សាហកម្មត្រូវបានគេហៅថា "ជាបង្គុំនៃបន្ទាត់ ឬពណ៌ ឬទម្រង់បីខ្នាត ឬសម្ភារៈណាមួយ ទោះបីជាមានរឺពុំមាន ការផ្តុំរួមជាបន្ទាត់ រឺពណ៌ក៏ដោយឲ្យតែមានការផ្តុំជាទម្រង់ ឬសំភារៈទាំងនោះរំលេចឡើងជារូបរាងពិសេសរបស់ផលិតផលឧស្សាហកម្ម រឺសិប្បកម្មដែលអាចធ្វើជាគំរូផលិតផល និងអាចសំគាល់ដោយវត្ថុបាន។ ត្រូវគេហៅថាជាម៉ាកច្បាប់នៃម៉ាកកម្ពុជាការពារតែទៅលើម៉ាកដែលអាចមើលឃើញតែប៉ុណ្ណោះ ប៉ុន្តែនៅប្រទេសមួយចំនួនមានការការពារលើម៉ាកដែលមិនអាចមើលឃើញដូចជាសំឡេង ក្លិន រស់ជាតិ ជាដើម។[11] ម៉ាកសមូហភាព ជាម៉ាកមួយដែលត្រូវបានគ្រប់គ្រងដោយសហគមន៍ម៉ាកសមូហភាព ដែលត្រូវបានកំណត់ដោយបញ្ញត្តិដោយឡែក។

ម៉ាកបញ្ជាក់ប្រភពដើមទំនិញម៉ាកប្រភេទនេះបុគ្គលណាក៏មានសិទ្ធិប្រើប្រាស់ដែរ ដោយគ្រាន់តែគោរពតាមលក្ខខណ្ឌតម្រូវដោយច្បាប់ស្តីពីស្តង់ដារ ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ (GIs)[12]ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញត្រូវបានកំណត់និយមន័យថា "ជាឈ្មោះ សញ្ញា ឬសញ្ញាផ្សេងទៀតដែលត្រូវបានប្រើប្រាស់ដើម្បីហៅ ឬតំណាងប្រភពភូមិសាស្ត្រ និងអាចកំណត់ប្រភពដើមនៃផលិតផលដែលមានគុណភាព កេរ្តិ៍ឈ្មោះ ឬចរិកលក្ខណៈផ្សេងទៀតនៃផលិតផលដែលជាប់ពាក់ព័ន្ធជាពិសេសទៅនិងលក្ខណៈដើមនៃភូមិសាស្ត្រ។

ក្នុងវិស័យឧស្សាហកម្មមានកម្មសិទ្ធិបញ្ញាជាច្រើនដែលត្រូវតែទទួលបានការការពារដូចខាងលើប្រសិនបើក្រុមហ៊ុនមិនបានយល់ដឹងពីកម្មសិទ្ធិបញ្ញាឬរបៀបប្រើប្រព័ន្ធកម្មសិទ្ធិឲ្យបានត្រឹមត្រូវ

[11] ច្បាប់ស្តីពីម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែញមិនស្មោះត្រង់, លេខ សន/រកម/០២០២/០០៦, ០៧ កុម្ភៈ ២០០២, មាត្រា២។

[12] ប្រកាសស្តីពីនីតិវិធីសម្រាប់ចុះបញ្ជី និងការពារម៉ាកដែលរួមបញ្ចូលទាំងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ, លេខ ១០៥ម សភ/ប្រក, ១៨ ឧសភា ឆ្នាំ២០០៩។

នោះនិងអាចខាតបង់ផលប្រយោជន៍ និងអាចបាត់បង់ចំណូលពីការលក់និងចំណូលពីផលិតផលកម្មសិទ្ធិបញ្ញា។

### ១.២.២. កម្មសិទ្ធិអក្សរសាស្ត្រ និងសិល្បៈ

កម្មសិទ្ធិអក្សរសាស្ត្រនិងសិល្បៈត្រូវបានបែងចែកជា២ដែលមាន សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល។ អ្នកនិពន្ធគឺជាជនដែលបានបង្កើតស្នាដៃអ្វីមួយផ្នែកអក្សរសាស្ត្រ សិទ្ធិអ្នកនិពន្ធគឺជាសិទ្ធិរបស់ម្ចាស់ស្នាដៃដែលទទួលផ្តាច់មុខលើស្នាដៃទាំងឡាយរបស់ខ្លួនហើយជាសិទ្ធិដែលជនគ្រប់រូបត្រូវទទួលស្គាល់សិទ្ធិនោះដែលរួមមានសិទ្ធិសីលធម៌ និងសិទ្ធិបេតិកភ័ណ្ឌ។

អ្នកនិពន្ធគឺជាជនដែលបានបង្កើតស្នាដៃអ្វីមួយផ្នែកអក្សរសាស្ត្រ សិទ្ធិអ្នកនិពន្ធគឺជាសិទ្ធិរបស់ម្ចាស់ស្នាដៃដែលទទួលផ្តាច់មុខលើស្នាដៃទាំងឡាយរបស់ខ្លួនហើយជាសិទ្ធិដែលជនគ្រប់រូបត្រូវទទួលស្គាល់សិទ្ធិនោះដែលរួមមានសិទ្ធិសីលធម៌ និងសិទ្ធិបេតិកភ័ណ្ឌ។[13] សិទ្ធិសីលធម៌ ជាសិទ្ធិអចិន្ត្រៃយ៍មិនអាចលក់ដូរ មិនអាចរឹបអូសបាន មិនអាចផុតអាជ្ញាយុកាលនៅក្នុងសិទ្ធិនេះអ្នកនិពន្ធអាចមានសិទ្ធិ សិទ្ធិផ្សព្វផ្សាយស្នាដៃជាសាធារណៈ សិទ្ធិកំណត់បង្ហាញឈ្មោះអ្នកនិពន្ធ សិទ្ធិរក្សាខ្លឹមសារស្នាដៃ សិទ្ធិបេតិកភណ្ឌ ជាសិទ្ធិដែលអាចទទួលបានជាប្រាក់កាសសិទ្ធិប្រកបអាជីវកម្មរបស់អ្នក និពន្ធលើស្នាដៃរបស់ខ្លួន តាមរយៈការផលិតឡើងវិញ ការផ្សព្វផ្សាយជាសាធារណៈ និងការបង្កើតស្នាដៃបន្តនិងអាចទទួលបានសិទ្ធិសិទ្ធិផលិតឡើងវិញ សិទ្ធិសម្តែង សិទ្ធិបញ្ចាំង សិទ្ធិបញ្ជូនជាសាធារណៈ សិទ្ធិសូត្រ សិទ្ធិតាំងពិព័រណ៍ សិទ្ធិផ្ទេរកម្មសិទ្ធិ សិទ្ធិចែកចាយ និងជួល សិទ្ធិបកប្រែ សម្រួល កែសម្រួល និងយកលំនាំតាម សិទ្ធិធ្វើអាជីវកម្មលើស្នាដៃបន្ត ។ គឺជាសិទ្ធិទាំងឡាយដែលរដ្ឋទទួលស្គាល់តាមបទប្បញ្ញត្តិច្បាប់ និងអាចអនុវត្តបានដោយអ្នកសំដែង ផលិតករហ្វូណូក្រាម ផលិតករវីឌីអូរ និងអង្គភាពទូរផ្សាយចំពោះស្នាដៃរបស់ខ្លួន។ សិទ្ធិប្រហាក់ប្រហែលមានសិទ្ធិអ្នកសម្តែង សិទ្ធិរបស់ផលិតករហ្វូណូក្រាម សិទ្ធិផលិតករវីដេអូសិទ្ធិនៃអង្គភាពទូរផ្សាយ។

អង្គភាពគ្រប់គ្រងសិទ្ធិរួមគឺជាអង្គភាពដែលធ្វើសកម្មភាពក្នុងគោលដៅតំណាងឲ្យម្ចាស់សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល។ អង្គភាពគ្រប់គ្រងសិទ្ធិរួមជា តំណាងស្របច្បាប់របស់ម្ចាស់សិទ្ធិអ្នក និពន្ធ និងម្ចាស់សិទ្ធិប្រហាក់ប្រហែលដែលជាសមាជិក។[14] គោលបំណងរបស់អង្គភាពគ្រប់គ្រងសិទ្ធិរួមព្រោះដោយសារតែម្ចាស់ស្នាដៃមានការលំបាក ក្នុងការគ្រប់គ្រងសិទ្ធិរបស់ខ្លួនជា

[13] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល , លេខ សន/រកម/០៣០៣/០០៨, ១៨ កុម្ភៈ ២០០៣, មាត្រា៦៩។
[14] សេចក្តីព្រាងអនុក្រឹត្យស្តីពី អង្គភាពគ្រប់គ្រងសិទ្ធិរួម, មាត្រា៥។

លក្ខណៈបុគ្គល ទើបនាំឲ្យពួកគាត់រួមគ្នាបង្កើតជាអង្គភាពមួយឈ្មោះថា អង្គភាពគ្រប់គ្រងសិទ្ធិរួម។ អង្គភាពនេះធ្វើសកម្មភាពក្នុងនាម និងដើម្បីផលប្រយោជន៍របស់អ្នកនិពន្ធ និងម្ចាស់សិទ្ធិប្រហាក់ប្រហែល។

## ១.៣. តារាងរយៈពេលនៃការការពារកម្មសិទ្ធិបញ្ញា

តារាងសង្ខេបខាងក្រោមមានជួរដេកបី និងជួរឈរដប់ដែលជួរឈរបានរៀបរាប់អំពីឈ្មោះកម្មសិទ្ធិបញ្ញាដែលត្រូវបានការពារ ដូចជាម៉ាក ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនប័ត្រម៉ូដែលមានអត្ថប្រយោជន៍ គំនូរឧស្សាហកម្ម សិទ្ធិអ្នកបង្កាត់ពូជដំណាំ ផលិតករហ្វូណូក្រាម សិទ្ធិអ្នកសម្តែង និងស្នាដៃនិពន្ធដែលមានរៀបរាប់ដូចខាងក្រោម៖

| ល.រ | ពិពណ៌នាឈ្មោះដែលត្រូវការពារ | រយៈពេលការពារ |
|---|---|---|
| ១. | ម៉ាក | ១០ ឆ្នាំហើយអាចទៀតបាន[15] |
| ២. | ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ | មិនកំណត់រយៈពេល |
| ៣. | ប្រកាសនីយបត្រតក្កកម្ម | ២០ ឆ្នាំរាប់ពីថ្ងៃខែដាក់ពាក្យ[16] |
| ៤. | វិញ្ញាបនប័ត្រម៉ូដែលមាន អត្ថប្រយោជន៍ | ៧ ឆ្នាំរាប់ពីថ្ងៃខែដាក់ពាក្យ[17] |
| ៥. | គំនូរឧស្សាហកម្ម | ៥ ឆ្នាំរាប់ពីថ្ងៃខែដាក់ពាក្យអាចដាក់ពាក្យសារឡើង វិញពីរដង សរុប : ១៥ ឆ្នាំ[18] |

[15] ច្បាប់ស្តីពីម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជេញមិនស្មោះត្រង់, លេខ សន/រកម/០២០២/០០៦, ០៧ កុម្ភៈ ២០០២, មាត្រា១២។

[16] ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្មវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍និងគំនូរឧស្សាហកម្ម, លេខ សន/រកម/០១០៣/០០៥, ០៦ ធ្នូ ២០០២, មាត្រា៤២។

[17] ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្មវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍និងគំនូរឧស្សាហកម្ម, លេខ សន/រកម/០១០៣/០០៥, ០៦ ធ្នូ ២០០២, មាត្រា៧៣។

[18] ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្មវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍និងគំនូរឧស្សាហកម្ម, លេខ សន/រកម/០១០៣/០០៥, ០៦ ធ្នូ ២០០២, មាត្រា១០៩។

| | | |
|---|---|---|
| ៦. | សិទ្ធិអ្នកបង្កាត់ពូជដំណាំ | ២០ ឆ្នាំរាប់ពីថ្ងៃខែបង្កាត់ និង ២៥ សំរាប់ដើមឈើ និងដើមទំពាំងបាយជូរ[19] |
| ៧. | ស្នាដៃនិពន្ធ | អស់មួយជីវិតអ្នកនិពន្ធ និង៥០ ឆ្នាំរាប់ពីថ្ងៃនិពន្ធបានស្លាប់[20] |
| ៨. | អ្នកសម្តែង | ៥០ ឆ្នាំរាប់ពីបំណាច់ឆ្នាំប្រក្រដីទិន ដែលបានថតបញ្ចូលក្នុងហ្វូណូក្រាម[21] |
| ៩. | ផលិតករហ្វូណូក្រាម | ៥០ ឆ្នាំរាប់ពីបំណាច់ឆ្នាំប្រក្រដីទិន ដែលបានបោះផ្សាយក្នុងហ្វូណូក្រាម[22] |

នៅក្នុងតារាងខាងលើសង្ខេបពីការទទួលបានការការពារ និងរយៈពេលដែលត្រូវការពារសំរាប់កម្មសិទ្ធិបញ្ញានីមួយៗដែលត្រូវបានដកស្រង់ចេញពីប្រភពច្បាប់ផ្សេងៗគ្នា។ ក្នុងរយៈពេលការការពារកម្មសិទ្ធិបញ្ញាទាំងនេះមានលក្ខណៈស្របតាមច្បាប់អន្តរជាតិ។

[19] ច្បាប់ស្តីពីការគ្រប់គ្រងពូជន៍ដំណាំនិងសិទ្ធិអ្នកបង្កាត់ពូជដំណាំ, លេខ សន/រកម/០៥០៨/០១៥, ២៩ មេសា ២០០៨, មាត្រា១៩។

[20] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល , លេខ សន/រកម/០៣០៣/០០៨, ១៨ កុម្ភៈ ២០០៣, មាត្រា៣០។

[21] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល , លេខ សន/រកម/០៣០៣/០០៨, ១៨ កុម្ភៈ ២០០៣, មាត្រា៥៣.១។

[22] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល , លេខ សន/រកម/០៣០៣/០០៨, ១៨ កុម្ភៈ ២០០៣, មាត្រា៥៣.២។

# ជំពូកទី២ នីតិវិធីនៃការចុះបញ្ជីកម្មសិទ្ធិបញ្ញា

ការចុះបញ្ជីកម្មសិទ្ធិបញ្ញានៅកម្ពុជាបច្ចុប្បន្នមានភាពលំបាកព្រោះយើងពុំទាន់មានច្រកចេញចូលតែមួយដើម្បីចុះបញ្ជីលើគ្រប់ការបង្កើតនូវគំនិតបញ្ញានោះទេគឺយើងមានក្រសួងបីសំរាប់ចុះបញ្ជីលើកម្មសិទ្ធិបញ្ញាផ្សេងៗពីគ្នា។ ការចុះបញ្ជីកម្មសិទ្ធិបញ្ញាសំខាន់នៅកម្ពុជាមានបីសំខាន់ក្នុងនោះមាន ម៉ាក ប្រកាសនីយបត្រតក្កកម្ម ឬវិញ្ញាបនប័ត្រម៉ូដែលមានអត្ថប្រយោជន៍ និងសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល។ ខាងក្រោមជានីតិវិធីលំអិតស្តីពីការចុះបញ្ជីនីមួយៗដែលមានជាដំណាក់កាលដូចតទៅៈ

## ២.១. ការចុះបញ្ជីម៉ាក

ការចុះបញ្ជីម៉ាកនៅក្នុងឆ្នាំ១៩៩១ដល់ឆ្នាំ១៩៩៧ គឺត្រូវទៅចុះនៅនាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេសការិយាល័យទំនាក់ទំនងអន្តរជាតិ ក្រសួងពាណិជ្ជកម្មដែលក្នុងនោះមានអ្នកធ្វើការចំនួន ២៥នាក់ ដែលធ្វើការងាររួម បូករួមទាំងការចុះបញ្ជីកម្មសិទ្ធិបញ្ញាផងដែរ។ ការវិវត្តបីឆ្នាំម្តងៗការចុះបញ្ជីម៉ាក់សព្វថ្ងៃនេះមានភាពទំនើបដែលត្រូវបានប្រើប្រាសដោយបច្ចេកវិទ្យាកុំព្យូទ័រ (ប្រព័ន្ធ IPAS[23]) ហើយមានអ្នកធ្វើការរហូតដល់ ៧៥នាក់ដែលធ្វើការសំរាប់តែការចុះបញ្ជីម៉ាក។ ដើម្បីធ្វើការចុះបញ្ជីម៉ាក់មួយគឺត្រូវឆ្លងកាត់នីតិវិធី ប្រាំបួនដំណាក់កាលធំៗមាន ដំណាក់កាលនៃការដាក់ពាក្យ ដំណាក់កាលនៃការទទួលស្គាល់ការដាក់ពាក្យ ដំណាក់កាលត្រួតពិនិត្យបែបបទ ដំណាក់កាលនៃការត្រួតពិនិត្យលំអិត ដំណាក់កាលនៃការចុះបញ្ជី ដំណាក់កាលនៃការបោះផ្សាយ ដំណាក់កាលនៃការច្រានចោលការចុះបញ្ជី ដំណាក់កាលនៃការប្តឹងជំទាស់ ដំណាក់កាលសវនាការ ។ នៅក្នុងដំណាក់កាលទាំងប្រាំបួននេះដំណាក់កាលខ្លះអាចត្រូវបានរំលង ឬបង្រួមចូលគ្នាជាបួនដំណាក់កាលធំៗដោយសារការមិនមានគ្រប់គ្រាន់នៅលក្ខខណ្ឌច្បាប់ ឬកង្វះខាតបទដ្ឋានគតិយុត្តិនានាស្តីពីការចុះបញ្ជី។ ម៉ាក់មួយចំនួនត្រូវបានហាមឃាត់មិនឲ្យចុះបញ្ជីបើម៉ាកនោះមិនអាចសំគាល់លក្ខណៈខុសគ្នានៃទំនិញ ឬសេវា ម៉ាកដែលធ្វើអោយប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ទំនៀមទំលាប់ប្រពៃណីល្អរបស់ជាតិ ម៉ាកដែលអាចអោយសាធារណជនភាន់ច្រឡំ ម៉ាក

[23] IPAS = Intellectual Property Administration System.

ដែលដូចទៅនិងសញ្ញា សំខាន់ៗនៃអង្គការ ឬរដ្ឋណាមួយ ឬសញ្ញាជាតិ ទង់ជាតិ ម៉ាកដែលដូចឬប្រហាក់ប្រហែលនិងម៉ាកល្បី ម៉ាកដែលចុះបញ្ជីមុនជាដើម។[24]

### ២.១.១. ដំណាក់កាលនៃការដាក់ពាក្យនិងទទួលស្គាល់ការដាក់ពាក្យ

ដំណាក់កាលនេះដំណាក់កាលមួយដំបូងបំផុតដែលអ្នកដាក់ពាក្យត្រូវចុះទៅកាន់ការិយាល័យរដ្ឋ បាលនិងទទួលចុះបញ្ជីម៉ាក នាយកដ្ឋានកម្មសិទ្ធិបញ្ញាក្រសួងពាណិជ្ជកម្មដើម្បីទទួលបាននៅគំរូពាក្យសុំ ។ នៅពេលដែលលក្ខខណ្ឌតំរូវការអប្បរមានៃការដាក់ពាក្យបានទទួលដោយការិយាល័យចុះបញ្ជីនោះអ្នកដាក់ពាក្យនិងទទួលបានលេខដាក់ពាក្យ ការកំណត់ថ្ងៃខែដាក់ពាក្យដែលត្រូវបានបោះពុម្ពចេញដោយស្វ័យប្រវត្តដោយប្រព័ន្ធ (IPAS) ។ លក្ខខណ្ឌតំរូវការអប្បរមានៃការដាក់ពាក្យដើម្បីបានកាលបរិច្ឆេទនៃការចុះបញ្ជីមានដូចជាៈ

ក. ឈ្មោះរបស់អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក
ខ. អសយដ្ឋានទំនាក់ទំនង
គ. គំរូម៉ាកដែលស្នើសុំចុះបញ្ជី
ឃ. យថាប្រភេទរបស់ទំនិញ ឬសេវាដែលស្នើសុំចុះបញ្ជីក្នុងចំណាត់ថ្នាក់នីមួយនៃ ទំនិញឬសេវាដែលស្នើសុំចុះបញ្ជី
ង. កម្រៃនៃការដាក់ពាក្យស្នើសុំចុះបញ្ជីដែលតំរូវសំរាប់ចំណាត់ថ្នាក់នីមួយៗ។[25]

### ២.១.២. ដំណាក់កាលនៃការត្រួតពិនិត្យបែបបទ និងការត្រួតពិនិត្យលំអិត

ដំណាក់កាលទាំងពីនេះជាដំណាក់កាលដែលត្រូវចំណាយរយៈពេលយូរ ជាផ្លូវការអ្នកត្រួតពិនិត្យ ត្រូវត្រួតពិនិត្យគ្រប់សំណុំឯកសារទាំងអស់ដែលបានដាក់ជូននៅថ្ងៃដាក់ពាក្យ។ មន្ត្រីត្រួតពិនិត្យម៉ាកត្រូវធ្វើការពិនិត្យតាមលំដាប់លំដោយទៅលើ តួអក្សរ ពាក្យ រូបសញ្ញា គ្រប់សមាសធាតុទាំងអស់ដែលបានការពារដោយធៀបនិងមាត្រា៤នៃច្បាប់ស្តីពីម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជេញមិនស្មោះត្រង់ និងពិនិត្យមើលថាតើពាក្យស្នើសុំនោះមានសុំសិទ្ធិអាទិភាពដែរឬទេ។ ការត្រួតពិនិត្យនេះវាគឺអាស្រ័យលើសមត្ថភាពនៃការឆ្លើយតបរបស់អ្នកដាក់ពាក្យ ពីព្រោះគាត់និងត្រូវបានទទួលដំណឹងរហ័សបំផុតតាមរយៈអ៊ីម៉ែល ដែលបានជូនដំណឹងដោយក្រសួងពាណិជ្ជកម្ម

[24] ច្បាប់ស្តីពីម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជេញមិនស្មោះត្រង់, លេខ សន/រកម/០២០២/០០៦, ០៧ កុម្ភៈ ២០០២, មាត្រា ៤។
[25] អនុក្រឹតស្តីពីការអនុវត្តច្បាប់ស្តីពីម៉ាកនិងអំពើនៃការប្រកួតប្រជេញមិនស្មោះត្រង់, លេខ៦៤អនក្រ/បក, ១២ កក្កដា ២០០៦, មាត្រា ១៦។

បើការឆ្លើយតបយឺតនោះដំណើរការក៏យឺតដែរ។ រយៈពេលមួយសប្តាហ៍ជារយៈមួយគ្រប់គ្រាន់ដើម្បីធ្វើការត្រួតពិនិត្យម៉ាកលំអិតនិងធ្វើការទទួលស្គាល់ជំហានបន្ទាប់ វាក៏អាចនិងយឺតយ៉ាវបើមានកង្វះឯកសារអប្បរមានៃការដាក់ពាក្យ។ ក្នុងករណីគ្មានបណ្តឹងជំទាស់ មន្ត្រីចុះបញ្ជី នឹងផ្តល់ការចុះបញ្ជីពី៤-៦ខែ។

## ២.១.៣. ដំណាក់កាលនៃការចុះបញ្ជី និងធ្វើការបោះផ្សាយ

ការចុះបញ្ជីម៉ាកមួយត្រូវមានតំរូវការឯកសារដូចជា៖

ក. គំរូម៉ាកដែលត្រូវបានចុះបញ្ជី
ខ. លេខដាក់ពាក្យ និង លេខចុះបញ្ជី
គ. ឈ្មោះនិងអសយដ្ឋានរបស់ម្ចាស់ម៉ាកដែលសុំចុះបញ្ជី
ឃ. ឈ្មោះនិងអសយដ្ឋានរបស់ភ្នាក់ង៉ាតំណាងប្រសិនបើមាន
ង. កាលបរិច្ឆេទនៃការដាក់ពាក្យនិងកាលបរិច្ឆេទចុះបញ្ជី
ច. បើសិនមានកាសុំសិទ្ធិអាទិភាពត្រូវមានការយល់ព្រមដោយមានបញ្ជាក់ឈ្មោះរដ្ឋ ឬប្រទេសនិងលេខដាក់ពាក្យដែលបានស្នើសុំលើកដំបូង
ឆ. ចំណាត់ថ្នាក់នៃការចុះបញ្ជីម៉ាក ត្រូវបញ្ជាក់ដោយស្របតាមចំណាត់ថ្នាក់អន្តជាតិ។[26]

ការយល់ព្រមទទួលឬការសម្រេចពីការចុះបញ្ជីនិងត្រូវបានផ្ញើទៅអ្នកដាក់ពាក្យឬភ្នាក់ងារដំណាងនៃម្ចាស់ម៉ាកស្របច្បាប់ក្រោយពីមានការសម្រេចចុងក្រោយពីប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា។ អ្នកដាក់ពាក្យ ឬភ្នាក់ងារដំណាងម្ចាស់ម៉ាកស្របច្បាប់ត្រូវបង់កម្រៃថ្លៃចុះបញ្ជីអំឡុងពេល ៦០ថ្ងៃបន្ទាប់ពីទទួលបានការយល់ព្រមពីការចុះបញ្ជី។ ការបោះពុម្ពផ្សាយនិងត្រូវបានចាប់ផ្តើមផ្សាយក្នុងការបោះផ្សាយតាមរយៈការជូនដំណឹងជាសាធារណៈនៅក្នុងសាពត៌មាន ដើម្បីអោយមានការប្តឹងជំទាស់និងត្រូវបានបោះពុម្ពក្នុងរយៈពេលមួយខែ។

## ២.១.៤ ដំណាក់កាលនៃការប្តឹងតវ៉ា ការប្តឹងជំទាស់ និងសវនាការ

បន្ទាប់ពីការពិចារណាពីការកែតម្រូវជាលាយលក្ខអក្សរ ពីអ្នកដាក់ពាក្យស្នើសុំការចុះបញ្ជី បើសិនមន្ត្រីកាន់កាប់បញ្ជីនៅតែបដិសេធការចុះបញ្ជី អ្នកដាក់ពាក្យសុំមានសិទ្ធិប្តឹងតវ៉ាពីការបដិសេធ

[26] អនុក្រឹតស្តីពីការអនុវត្តច្បាប់ស្តីពីម៉ាកនិងអំពើនៃការប្រកួតប្រជេញមិនស្មោះត្រង់, លេខ៦៤អនក្រ/បក, ១២ កក្កដា ២០០៦, មាត្រា ១៩.៣។

ការចុះបញ្ជីក្នុងរយៈពេលបីខែគិតពីថ្ងៃចេញសេចក្តីសម្រេចរបស់មន្ត្រីកាន់កាប់បញ្ជី។ [27] ក្រៅពីយន្តការដែលជាចំណាក់ការរបស់តុលាការចំពោះអំពើរំលោភសិទ្ធិតុលាការមានសមត្ថកិច្ចក្នុងការចាត់នីតិវិធីចំពោះបណ្តឹងរដ្ឋបាលប្រឆាំងនឹងសេចក្តីសម្រេចរបស់មន្ត្រីកាន់កាប់បញ្ជីពាក់ព័ន្ធ ដែលជាសេចក្តីសម្រេចរដ្ឋបាលផងដែរ។ បណ្តឹងនេះជាប្រភពនៃបណ្តឹងរដ្ឋបាលមួយដែលជាសមត្ថកិច្ចរបស់តុលាការនៃនីតិរូមផងដែរ។

ក្រោយពីការចុះបញ្ជីម្ចាស់ម៉ាកអាចមានសិទ្ធិធ្វើការផ្លាស់ប្តូរម្ចាស់កម្មសិទ្ធិម៉ាកកើតឡើងនៅពេលដែល ភាពជាម្ចាស់កម្មសិទ្ធិម៉ាក ត្រូវបានផ្ទេរពីភាគីមួយ ទៅភាគីមួយផ្សេងទៀត ឬម្ចាស់សិទ្ធិចូលរួមជាមួយអង្គភាពផ្សេងទៀតម្ចាស់សិទ្ធិលក់ ឬផ្ទេរសិទ្ធិកាន់កាប់ម៉ាករបស់ខ្លួនទៅអោយអង្គភាពផ្សេងទៀត។ ការផ្លាស់ប្តូរម្ចាស់កម្មសិទ្ធិម៉ាក អាចស្ថិតក្រោមជាទម្រង់ពេញលេញ ឬមួយផ្នែក ការផ្លាស់ប្តូរកម្មសិទ្ធិម៉ាកពេញលេញ ទាក់ទងគ្រប់ទំនិញ ឬសេវាទាំងឡាយណា ដែលគ្របដណ្តប់ដោយ ពាណិជ្ជសញ្ញានោះការផ្លាស់ប្តូរកម្មសិទ្ធិម៉ាកមួយផ្នែកៈ ទាក់ទងតែទៅនឹងមុខទំនិញ ឬសេវាមួយចំនួនតែប៉ុណ្ណោះ។ ដើម្បីកត់ត្រា ការផ្ទេរម្ចាស់កម្មសិទ្ធិម៉ាក តាមដែលអាចធ្វើទៅបាន ម្ចាស់សិទ្ធិត្រូវ ជូនដំណឹងមន្ត្រីកាន់កាប់បញ្ជីជាលាយលក្ខណ៍អក្សរ បញ្ជាក់ឲ្យបានច្បាស់ ពីពាណិជ្ជសញ្ញាដែលត្រូវផ្លាស់ប្តូរ ផ្តល់ឯកសារភស្តុតាងបញ្ជាក់ពីភាពជាម្ចាស់សិទ្ធិដូចជាៈ លិខិតផ្តល់សិទ្ធិ ឯកសារនៃការរួមបញ្ចូលក្រុមហ៊ុន លិខិតផ្តល់សិទ្ធិធម្មតា ឯកសារសុពលកម្ម ឬសេចក្តីប្រកាស រាយមុខទំនិញ ឬសេវា ដែលត្រូវផ្ទេរសិទ្ធិ ក្នុងករណីនៃការផ្ទេរសិទ្ធិដោយផ្នែក។ ការទទួលខុសត្រូវជាបន្ទុករបស់ភាគី ដែលពាក់ព័ន្ធ ដើម្បីធានាថាការផ្លាស់ប្តូរម្ចាស់កម្មសិទ្ធិ នឹងមិនបង្កឲ្យមានការបោកបញ្ឆោតឬការភាន់ច្រឡំ។

## ២.២. ប្រកាសនីយបត្រតក្កកម្ម ឬវិញ្ញាបនប័ត្រម៉ូដែលមានអត្ថប្រយោជន៍

ការដាក់ពាក្យសុំចុះបញ្ជីប្រកាសនីយបត្រតក្កកម្មឬ វិញ្ញាបនប័ត្រម៉ូដែលមានអត្ថប្រយោជន៍ត្រូវធ្វើឡើងនៅ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ដែលក្នុងនោះត្រូវរួមមាន ពាក្យសុំសេចក្តីអធិប្បាយអំពីតក្កកម្ម សេចក្តីអះអាង គំនូសបង្ហាញប្រសិនបើចាំបាច់និងខ្លឹមកសារសង្ខេប។ ការដាក់សំណុំលិខិតស្នើសុំត្រូវតែមានការបង់កម្រៃតាមការកំណត់។ ពាក្យសុំត្រូវមានបញ្ជាក់អំពីអ្វីដែលអាចឈានទៅដល់ការផ្តល់ប្រកាសនីយបត្រតក្កកម្មបាន ដូចជានាម និងទិន្នន័យផ្សេងៗដែលពាក់ព័ន្ធទៅនឹងអ្នកដាក់ពាក្យសុំតក្កករ និងភ្នាក់ងារតំណាងប្រសិនបើមាន និងចំណងជើងនៃតក្ក

[27] អនុក្រឹតស្តីពីការអនុវត្តច្បាប់ស្តីពីម៉ាកនិងអំពើនៃការប្រកួតប្រជេញមិនស្មោះត្រង់, លេខ៦៤អនក្រ/បក, ១២ កក្កដា ២០០៦, មាត្រា ១៨។

កម្មនោះ។ ក្នុងករណីអ្នកដាក់ពាក្យសុំមិនមែនជាតក្កករទេនោះ ពាក្យសុំត្រូវតែភ្ជាប់មកជាមួយនូវឯកសារបញ្ជាក់ អំពីសិទ្ធិរបស់អ្នកដាក់ពាក្យសុំ ចំពោះប្រកាសនីយបត្រតក្កកម្ម។ សេចក្តីអធិប្បាយត្រូវលើកបង្ហាញអំពីតក្កកម្មក្នុងលក្ខណៈច្បាស់លាស់ និងពេញលេញ ដើម្បីឱ្យបុគ្គលដែលមានកម្រិតជំនាញធម្មតាក្នុងជំនាញអាចអនុវត្តបាននូវតក្កកម្មនោះ។ ដោយឡែកសេចក្តីអធិប្បាយនោះត្រូវចង្អុលបង្ហាញឱ្យដឹងនូវវិធីដែលល្អជាងគេដើម្បីអនុវត្តតាមបាននូវតក្កកម្មខាងលើនៅពេលចុះកាលបរិច្ឆេទ សុំចុះបញ្ជី ឬនៅពេលចុះកាលបរិច្ឆេទអាទិភាព នៃសំនុំលិខិតស្នើសុំក្នុងករណីអាទិភាពត្រូវបានអះអាង។ សេចក្តីអះអាងត្រូវតែកំណត់ឱ្យយបានច្បាស់លាស់ អំពីចំណុចដែលសុំឱ្យមានការការពារ។ សេចក្តីអធិប្បាយនិងគំនូសបង្ហាញអាចត្រូវយកទៅប្រើប្រាស់បានសម្រាប់ធ្វើការ បកស្រាយ សេចក្តីអះអាងនោះ។ សេចក្តីអះអាងត្រូវតែច្បាស់លាស់ និងសង្ខេប។ សេចក្តីអះអាងនោះត្រូវតែផ្អែកទាំងស្រុងលើសេចក្តីអធិប្បាយ។ គំនូសបង្ហាញចាំបាច់ត្រូវតែមានដើម្បីយកមកបកស្រាយពន្យល់អំពីតក្កកម្មនោះ។ ខ្លឹមសារសង្ខេបត្រូវបកស្រាយត្រឹមតែគោលបំណងនៃព័ត៌មានបច្ចេកទេសតែប៉ុណ្ណោះ មិនត្រូវបកស្រាយអំពីវិសាលភាពនៃការការពារឡើយ។ អ្នកដាក់ពាក្យសុំអាចដកសំណុំលិខិតស្នើសុំទៅវិញនៅពេលណាក៏បានក្នុងករណីដែលសំណុំលិខិតស្នើសុំនោះស្ថិតក្នុងរយៈពេលព្យួរទុកសម្រាប់ពិនិត្យ ដើម្បីផ្តល់ប្រកាសនីយបត្រតក្កកម្ម។

ក្នុងវិស័យពាណិជ្ជកម្ម ព័ត៌មាននៃផលិតផលមានពីរប្រភេទគឺ ព័ត៌មានដែលអាចចុះបញ្ជីការពារប្រកាសនីយបត្រតក្កកម្មបាន និងព័ត៌មានដែលមិនអាចចុះបញ្ជីប្រកាសនីយបត្រតក្កកម្មបាន។ ព័ត៌មានដែលអាចចុះបញ្ជីប្រកាសនីយបត្រតក្កកម្មបាន មានដូចជា ព័ត៌មានទាក់ទងនឹងផលិតផល ឬព័ត៌មាននៃដំណើរការផលិត ដែលអាចចុះបញ្ជីប្រកាសនីយបត្រតក្កកម្ម។[28] ទន្ទឹមនេះផងដែ មានព័ត៌មានមួយចំនួនទៀត ដែលច្បាប់មិនអនុញ្ញាតឲ្យចុះបញ្ជីបាន ប្រកាសនីយបត្រតក្កកម្មមានជាអាទិ៍ រូបមន្ត គម្រោង ផែនការ វិធីសាស្ត្រធ្វើពាណិជ្ជកម្ម។[29]

## ២.៣. សិទ្ធិអ្នកនិពន្ធ

សិទ្ធិអ្នកនិពន្ធជាសិទ្ធិដែលផ្តល់ឱ្យដោយច្បាប់ដល់អ្នកនិពន្ធ សិល្បៈករឬអ្នកបង្កើតស្នាដៃផ្សេងៗទៀត ក្នុងការប្រើប្រាស់និងការពារស្នាដៃរបស់ខ្លួន។ ពាក្យកិច្ចការពារមានន័យថា ជា

[28] ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្មវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍និងគំនូរឧស្សាហកម្ម, លេខ សន/រកម/០១០៣/០០៥, ០៦ ធ្នូ ២០០២, មាត្រា១។

[29] ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្មវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍និងគំនូរឧស្សាហកម្ម, លេខ សន/រកម/០១០៣/០០៥, ០៦ ធ្នូ ២០០២, មាត្រា៩។

សកម្មភាពស្របច្បាប់ណាមួយក្នុងការបង្ការស្នាដៃពីការចម្លងដោយគ្មានការអនុញ្ញាត ឬការយល់ព្រមជាមុនពីផលិតករ។ កិច្ចការពារស្នាដៃគឺសំដៅទៅលើស្នាដៃការសរសេរឬការសម្ដែងចេញពីគំនិតមិនមែនការពារទៅលើយោបល់នោះទេ។

ការចុះបញ្ជីលើសិទ្ធិអ្នកនិពន្ធត្រូវធ្វើឡើងតាមគោលការស្ម័គ្រចិត្តនៅក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដែលការចុះបញ្ជីនេះត្រូវចុះឈ្មោះពិតប្រាកដរបស់អ្នកនិពន្ធ ចុះថ្ងៃខែឆ្នាំ នៃស្នាដៃដែលបានផ្សព្វផ្សាយលើកដំបូង និងចុះថ្ងៃខែឆ្នាំដែលបានបង្កើតស្នាដៃ និងត្រូវចុះពីសិទ្ធិរបស់អ្នកនិពន្ធ។ ស្នាដៃទាំងឡាយដែលមិនបានចុះបញ្ជីក៏ត្រូវបានទទួលកិច្ចការពារដោយស្វ័យប្រវត្ត។[30]

នៅប្រទេសកម្ពុជាដោយសារច្បាប់ពុំបានកំណត់ច្បាស់លាស់ថាគំនូរឧស្សាហកម្មត្រូវការពារដោយច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធតែបានឲ្យនិយមន័យអំពីស្នាដៃដែលអាចត្រូវទទួលបានការការពារក្នុងនោះក៏មានស្នាដៃជាផ្ទាំងគំនូរ ដូចនេះអ្នកប្រកបអាជីវកម្មអាចធ្វើការជ្រើសរើសការការពាររបស់ខ្លួនស្របតាមផលប្រយោជន៍ដែលខ្លួនចង់បាន។

វិធានការនៃការការពារកម្មសិទ្ធិបញ្ញាបានត្រឹមត្រូវម្ចាស់កម្មសិទ្ធិអាចធ្វើបណ្ដឹងទៅ តុលាការដើម្បីចាត់វិធានការបណ្ដោះអាសន្ន ទប់ស្កាត់អំពើរំលោភសិទ្ធិដែលកំពុងកើតមានឬដែលបំរុងនិងកើតមាននាពេលខាងមុខក្នុងគោលដៅការពារផលប្រយោជន៍របស់ម្ចាស់សិទ្ធិនិងរក្សាទុកភស្តុតាងនៃអំពើរំលោភបំពាន។ ក្រៅពីយន្តការដែលជាចំណាក់ការរបស់តុលាការចំពោះអំពើរំលោភសិទ្ធិ តុលាការមានសមត្ថកិច្ច ក្នុងការចាត់នីតិវិធីចំពោះបណ្ដឹងរដ្ឋបាលប្រឆាំងនឹងសេចក្ដីសម្រេចរបស់មន្ត្រីកាន់កាប់បញ្ជីពាក់ព័ន្ធ ដែលជាសេចក្ដីសម្រេចរដ្ឋបាលផងដែរ។ បណ្ដឹងនេះជាប្រភពនៃបណ្ដឹងរដ្ឋបាលមួយដែលជាសមត្ថកិច្ចរបស់តុលារការនៃនីតិរួមផងដែរ។

[30] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល , លេខ សន/រកម/០៣០៣/០០៨, ១៨ កុម្ភៈ ២០០៣, មាត្រា៣៨។

# ជំពូកទី៣ អត្ថប្រយោជន៍នៃការចុះបញ្ជីកម្មសិទ្ធិបញ្ញា

ជាគោលការណ៍នៃកិច្ចការពាកម្មសិទ្ធិបញ្ញា ជាចំណុចសំខាន់ដែលធ្វើអោយមានទ្រព្យអរូបីក្លាយទៅជាសិទ្ធិទ្រព្យសម្បត្តិទាំងស្រុង ទោះបីមានរយៈពេលកំណត់ក៏ដោយ។ កិច្ចការពារកម្មសិទ្ធិអាចធ្វើអោយអាជីវកម្ម អាចទាមទារកម្មសិទ្ធិលើ ទ្រព្យអរូបីហើយអាចប្រើក្នុងសក្តានុពលជាអតិបរិមាបាន។ ការការពារកម្មសិទ្ធិបញ្ញាអាចធ្វើអោយទ្រព្យអរូបីមាន រូបភាពច្បាស់លាស់មួយកំរិតតាមរយៈការធ្វើអោយទ្រព្យនេះមានតំលៃទាំងស្រុង ដែលគេអាចជួញដូរក្នុងទីផ្សារបាន។ អ្នកវិនិយោគទុននានា អាជីវករផ្សារភាគហ៊ុន និងទីប្រឹក្សាហិរញ្ញវត្ថុកាន់តែយល់ច្បាស់អំពីការពិតនេះ និងចាប់ផ្តើអោយតំលៃខ្ពស់លើកម្មសិទ្ធិបញ្ញា។ ក្រុមហ៊ុននានាទូទាំងពិភពលោកក៏ទទួលស្គាល់តំលៃរបស់គេកាន់តែច្បាស់ឡើងៗ។ ក្នុងនោះអាជីវកម្មជាច្រើនរួមទាំង ខ្នាតតូច មធ្យម បានកំពុងចាប់ផ្តើមធ្វើសវនកម្មលើបច្ចេកវិទ្យា និងកម្មសិទ្ធិរបស់ពួកគេយ៉ាងទៀងទាត់។[31]

## ៣.១. អត្ថប្រយោជន៍ចំពោះសង្គម

កិច្ចការពារផ្នែកកម្មសិទ្ធិបញ្ញា ជាកត្តាសំខាន់បំផុត សំរាប់អភិវឌ្ឍន៍វិស័យសេដ្ឋកិច្ចជាតិ ឲ្យមានភាពរីកចំរើន ជាពិសេសការពារពាណិជ្ជករ អ្នកវិនិយោទុនដែលចង់មកធ្វើអាជីវកម្ម គឺធានាឲ្យបាននូវកំណើន ពាណិជ្ជកម្មជាអតិបរិមា ទាំងសហគ្រាសខ្នាតតូច និងមធ្យម ពីព្រោះថា ក្រុមហ៊ុនសហគ្រាសតូច ធំទាំងអស់ តែងតែមាន ពាណិជ្ជសញ្ញា ម៉ាក ព្រមទាំងការពារការសម្ងាត់ពាណិជ្ជកម្មជាដើម។[32] ការជម្រុញគោលនយោបាយរាជរដ្ឋាភិបាលក្នុងការបង្កើតតក្កកម្ម ឬប្រឌិតឡើងផ្សព្វផ្សាយនិងអនុវត្តន៍លទ្ធផល និងលើកទឹកចិត្តពាណិជ្ជកម្មស្មោះត្រង់ដែលជាការរួមចំណែកដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមជាតិទាំងមូល។ ជាទូទៅច្បាប់កម្មសិទ្ធិបញ្ញា មានគោលបំណងការពារអ្នកបង្កើត និងអ្នកដទៃទៀត ដែលជាផលិតករនៃផលិតផល និងសេវាដែលកើតចេញពីបញ្ញាដោយផ្តល់ឲ្យគេនូវសិទ្ធិក្នុងរយៈពេលកំណត់មួយ ដើម្បីត្រួតត្រា ការប្រើប្រាស់ផលិតផល ដែលកើតចេញពីផលិតកម្មទាំងនោះ។[33] ការជម្រុញឲ្យមានអ្នកវិនិយោគទុន មកធ្វើពាណិជ្ជកម្ម ជាគោលដៅនៃការអភិវឌ្ឍប្រទេសជាតិ ឲ្យមានភាពរីកចំរើនជាអតិបរិមា សំរាប់អភិវឌ្ឍសង្គមទាំងមូល។ ទន្ទឹមនឹងការទាក់ទាញអ្នកវិនិយោគទុនមកបង្កើតក្រុមហ៊ុននោះ គឺត្រូវធានាអ្នកវិយោគទាំងនោះទទួល

[31] ក្រសួងពាណិជ្ជកម្ម កម្មសិទ្ធិបញ្ញា និង ការអភិវឌ្ឍផ្នែកសេដ្ឋកិច្ច, ទំព័រ៥។

32 ក្រសួងពាណិជ្ជកម្ម, កម្មសិទ្ធិបញ្ញា ទំព័រ២។

[33] ង៉ែត វិបុល នីតិកម្មសិទ្ធិបញ្ញា, ឆ្នាំ២០១៣-២០១៤ ទំព័រ១៤។

បានការពារពីច្បាប់កម្មសិទ្ធិបញ្ញា ដែលមានសារៈសំខាន់ក្នុងការប្រកួតប្រជែងក្នុងវិស័យពាណិជ្ជកម្មទាក់ទងទៅនឹងទំនិញ ឬសេវាកម្មដែលបានប្រើប្រាស់ម៉ាកបានចុះបញ្ជីហើយនោះ។[34]

កម្មសិទ្ធិបញ្ញាអាចបង្កើនតំលៃ ឬទ្រព្យធននៃអាជីវកម្មរបស់អ្នក តាមការទាក់ទាញអ្នកវិនិយោគទុន ឬ គ្រឹះស្ថានហិរញ្ញវត្ថុ។ ក្នុងករណីមានការលក់ ការបញ្ចូលក្រុមហ៊ុន ឬការបានជាកម្មសិទ្ធិទ្រព្យកម្មសិទ្ធិបញ្ញាអាចបង្កើនតំលៃសហគ្រាសបានយ៉ាងច្រើន ហើយភាគច្រើន គេចាត់ទុកជាទ្រព្យចំបង ឬទ្រព្យពិតដែលមានតំលៃ។

ការប្រើប្រាស់ទ្រព្យកម្មសិទ្ធិបញ្ញា ជាយុទ្ធសាស្ត្រ អាចបង្កើនលទ្ធភាពក្នុងការប្រគួតប្រជែងក្នុងមុខជំនួញ។ ទាំងអាជីវកម្មខ្នាត តូច និងមធ្យមត្រូវតែដឹងច្បាស់ថា ការប្រឈមមុខនិងឧបសគ្គហើយចាត់វិធានការដើម្បីប្រើប្រាស់ និងការពារកម្មសិទ្ធិបញ្ញាគ្រប់ពេលដែលអាចធ្វើទៅបាន។ ក្នុងនោះ កម្មសិទ្ធិករទាំងឡាយត្រូវតែទទួលបាន និងរក្សាទុក ទទួលខុសត្រូវ វាយតំលៃតាមដានយ៉ាងហ្មឹងម៉ាត់ និងចាត់ចែងទ្រព្យកម្មសិទ្ធិបញ្ញាយ៉ាងប្រយ័ត្ន ដើម្បីទាញយកផលប្រយោជន៍ទាំងស្រុងបានដោយឡែក មុននឹងអាចទាញយកផលប្រយោជន៍ទាំងនោះបាន គឺត្រូវតែទទួលស្គាល់តំលៃនៃកម្មសិទ្ធិបញ្ញា ហើយត្រូវមានគំនិតយល់ថា ជាទ្រព្យដ៏មានតំលៃ។

ការពារកម្មសិទ្ធិបញ្ញា មិនគ្រាន់តែទទួលបាននូវអត្ថប្រយោជន៍ការពារសិទ្ធ និងផលប្រយោជន៍សំរាប់អ្នកដែលបានបង្កើតស្នាដៃតែប៉ុណ្ណោះទេ គឺថែមទាំង ការពារពាណិជ្ជករ វិនិយោគទុនជាតិអន្តរជាតិ ការរក្សាសន្តិសុខ សុវត្ថិភាព ដល់ អ្នកវិនិយោគទុនទាំងនោះ ធ្វើឲ្យប្រទេសជាតិ មានភាពល្បីល្បាញខ្ទរខ្ទារ លើពិភពលោកទាំងមូល។ ជាងនេះទៅទៀត ទាំងអ្នកមានគំនិតបង្កើតជាស្នាដៃនឹងប្រទេសដែលមានលិខិតបទដ្ឋានគតិយុត្តិគ្រប់ជ្រុងជ្រោយ សំរាប់ការពារ ពាណិជ្ជករ ជាពិសេសមានច្បាប់ផ្នែកកម្មសិទ្ធិបញ្ញា អាចនិងជួយលុបបំបាត់ ឬទប់ស្កាត់ នៃអំពើទាំងឡាយដែលរំលោភបំពានកម្មសិទ្ធិបញ្ញាទាំងលើថ្នាក់ជាតិ និង លើឆាកអន្តរជាតិ ជារួម អាចនិយាយបានថាគោរពសិទ្ធិកម្មសិទ្ធិបញ្ញា ជាការចូលរួម ថែរក្សារ សុខសន្តិភាព ស្ថេរភាពខាងផ្នែក សេដ្ឋកិច្ចជាតិទំនាក់ទំនងពាណិជ្ជកម្ម ឲ្យទទួលបាននូវវឌ្ឍនភាពជាតិយ៉ាងក្រៃលែងបំផុតសំរាប់ប្រទេសជាតិទាំងមូល។[35]

---

[34] ច្បាប់ ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់,មាត្រា១១និង ក្រសួងពាណិជ្ជកម្ម, *កម្មសិទ្ធិបញ្ញា* ទំព័រ៦។
[35] ង៉ែត វិបុល, *នីតិកម្មសិទ្ធិបញ្ញា* ទំព័រ៣៥

ការកំណត់សម្គាល់លក្ខណៈភូមិសាស្ត្រមានសារៈសំខាន់ផ្នែកសេដ្ឋកិច្ចដ៏សំខាន់ទាំងនៅថ្នាក់ជាតិ និង អន្តរជាតិ។ ផលិតផលជាក់លាក់មួយចំនួនត្រូវបានទទួលស្គាល់ជាពិសេសដោយសាលក្ខណៈសម្បត្តិភូមិសាស្ត្រ ដូចជា ដី បរិយាកាស ឬ ជំនួញជាពិសេសរបស់ប្រជាជនដែលធ្វើឲ្យអ្នកប្រើប្រាស់ទិញផលិតផលនោះ ពីព្រោះគេរំពឹងថានឹងទទួលបានពីអ្វី ដែលគេជឿជាក់ពីផលិតផលរបស់ពួកគេ។[36]

ជាចំណុចសំខាន់ និងមានសារៈប្រយោជន៍ សំរាប់ ស្ថាប័នរបស់ជាតិគឺ ឲ្យមានភាពសកម្មក្នុងការខិតខំប្រឹងប្រែង និងទទួលផលផ្លែផ្កាពីការរៀបចំ និង ការអនុវត្តឲ្យមានប្រសិទ្ធភាពផ្នែកកម្មសិទ្ធិបញ្ញា ។ ក្នុងនោះចាប់ រដ្ឋសភាជាតិ ជាស្ថាប័នកំពូលដែលដែលមានសិទ្ធិ និងអំណាចកំណត់គោលនយោបាយ និង អនុម័តច្បាប់របស់ជាតិទាំងមូល។[37] ទន្ទឹមនឹងការនេះ ក៏មានស្ថាប័នជាតិ ដទៃផ្សេងទៀតដែលជាសេនាធិការ ដែលមានតួនាទីយ៉ាងសំខាន់ក្នុងការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញាប្រកបដោយ ប្រសិទ្ធិភាពខ្ពស់ ព្រមទាំងធានាឲ្យមាន ការវិនិយោគដោយតម្លាភាព ក្នុងមាននាមជាស្ថាប័នជាតិមួយដែល ដើរតួនាទីយ៉ាងសំខាន់បំផុតក្នុងការអនុវត្តច្បាប់ ក៏ដូចជា អភិវឌ្ឍន៍ជាតិឲ្យមានការរីកចំរើនជាអង្វែង។

## ៣.២. អត្ថប្រយោជន៍ចំពោះបុគ្គល

ជាមធ្យោបាយមួយដែលធ្វើឲ្យក្រុមហ៊ុនកាន់តែមានភាពរឹងមាំ ក្នុងការកំណត់ដើមទុនសំរាប់ការទទួលប្រាក់ចំណេញដែលមានសក្ដានុពលលើទ្រព្យកម្មសិទ្ធិបញ្ញា និងទាញយកតំលៃបានទាំងស្រុងគឺ ការធ្វើសវនកម្មលើកម្មសិទ្ធិបញ្ញា។ ដើម្បីទទួលបានលទ្ធផលល្អសវនកម្មនេះត្រូវធ្វើឡើងដោយសវនករខាងកម្មសិទ្ធិបញ្ញា ប៉ុន្តែជាញឹកញាប់អាចធ្វើសវនកម្មដំបូងដោយខ្លួនឯងបាន។ សវនកម្មគ្រាដំបូងនោះរួមមាន ការកំណត់អត្តសញ្ញាណ ការតាមដាន ការវាយតំលៃទ្រព្យកម្មសិទ្ធិបញ្ញាក្នុងធុរកិច្ចដើម្បីរកឲ្យឃើញថា បានប្រើអស់លទ្ធភាពហើយឬនៅ។ ដោយបង្កើតឡើងនូវវប្បធម៌មួយសំរាប់ចង្អុលបង្ហាញ និងបណ្ដុះទ្រព្យសម្បត្តិខាងបញ្ញារបស់មនុស្ស និងប្រើប្រាស់ទ្រព្យទាំងនោះជាយុទ្ធសាស្ត្រ សហគ្រាសមួយអាចបង្កើនផលចំណូលបានព្រមទាំងមានប្រៀបលើគូរប្រជែង និងអាចពង្រឹងជំហរបានយ៉ាងប្រសើរក្នុងទីផ្សារ។

[36] ក្រសួងពាណិជ្ជកម្ម កម្មសិទ្ធិបញ្ញា បោះពុម្ពដោយក្រសួងពាណិជ្ជ និង ធនាគារអភិវឌ្ឍន៍អាស៊ីឆ្នាំ២០០៨ ទំព័រ៦១។
[37] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣, មាត្រា ៩៣។

សារៈសំខាន់នៃការរកទីផ្សារការលក់ទំនិញ គឺទាមទារឲ្យមានការការពារ តាមរយៈ ច្បាប់កម្មសិទ្ធិបញ្ញា ដូចជាការគ្រប់គ្រងគុណភាពទំនិញ សុវត្ថិភាពលើផលិតផល ទំនិញ ព្រមទាំងសេវាកម្ម ក៏ដូចជា ការហាមដាច់ខាត រាល់ទំនិញទាំងឡាយណាដែលនាំ ឲ្យប៉ះពាល់ដល់សុខភាពសាធារណៈជនប្រើប្រាស់ និង ជាពិសេសផ្តោតសំខាន់លើ សហគ្រាស ពាណិជ្ជកម្មទំនិញដែលនាំចេញនាំចូលទំនិញគ្រប់ប្រភេទឲ្យមានការត្រួតពិនិត្យយ៉ាងត្រឹមត្រូវបំផុតនៅតាមតំបន់ព្រំដែន ព្រមទាំងហាមដាច់ខាត រាល់បណ្តាផលិតផល និងឧបករណ៍ ដែលសំដៅទៅលើ យកមកបំពេញកិច្ចបន្លំ ឬក្លែងមុខទំនិញទាំងឡាយ និង ហាមឃាត់ចំពោះការផ្សព្វផ្សាយពាណិជ្ជកម្មគ្រប់ប្រភេទណា ដែលមានលក្ខណៈ ភូតភរ ក្លែងបន្លំ ឬ ធ្វើអោយមានការភ័ន្តច្រឡំពីការពិត ។[38]

តំលៃនៃម៉ាកត្រូវបានចាត់ទុកថាជាទ្រព្យសម្បត្តិដ៏មានតំលៃ និងមានសក្តានុពលភាពបំផុតសម្រាប់ពាណិជ្ជកម្មរបស់សហគ្រាសមួយ។ ម៉ាកមួយកាន់តែមានតំលៃ ប្រសិនបើម៉ាកនោះក្លាយជាម៉ាកល្បី។ ដោយផ្អែកលើភាពល្បីនៃម៉ាកតាមរយៈកេរ្តិ៍ឈ្មោះ និងទំហំរូបភាពនៃការធ្វើអាជីវកម្មលើម៉ាកនោះ វានឹងផ្តល់តំលៃសេដ្ឋកិច្ចដ៏ធំធេងដល់ម្ចាស់ម៉ាកវិញ ដើម្បីអនុញ្ញាតឲ្យម្ចាស់ម៉ាកអាចមានលទ្ធភាពប្រកួតប្រជែងបន្តទៀតនៅក្នុងទីផ្សារផលិតផល ឬសេវាកម្ម។

ក្នុងវិស័យពាណិជ្ជកម្ម ព័ត៌មាននៃផលិតផលមានពីរប្រភេទគឺ ព័ត៌មានដែលអាចចុះបញ្ជីការពារប្រកាសនីយបត្រតក្កកម្មបាន និងព័ត៌មានដែលមិនអាចចុះបញ្ជីប្រកាសនីយបត្រតក្កកម្មបាន។ ព័ត៌មានដែលអាចចុះបញ្ជីប្រកាសនីយបត្រតក្កកម្មបាន មានដូចជា ព័ត៌មានទាក់ទងនឹងផលិតផល ឬព័ត៌មាននៃដំណើរការផលិត ដែលអាចចុះបញ្ជីប្រកាសនីយបត្រតក្កកម្ម។[39] ទន្ទឹមនេះផងដែ មានព័ត៌មានមួយចំនួនទៀត ដែលច្បាប់មិនអនុញ្ញាតឲ្យចុះបញ្ជីបាន ប្រកាសនីយបត្រតក្កកម្មមានជាអាទិ៍ រូបមន្ត គម្រោង ផែនការ វិធីសាស្ត្រធ្វើពាណិជ្ជកម្ម។[40]

## ៣.៣. អត្ថប្រយោជន៍ពីការចុះបញ្ជី

ក្រោយពីការចុះបញ្ជីកម្មសិទ្ធិបញ្ញានោះនិងទទួលបានសិទ្ធិផ្តាច់មុខលើកម្មសិទ្ធិដែលជាសិទ្ធិមួយសំរាប់អោយអ្នកទទួលបានការការពាតាមរយះពេលនៃកម្មសិទ្ធិបញ្ញា។ អ្នកនិពន្ធទទួលបានសិទ្ធិផ្តាច់មុខលើស្នាដៃ សិទ្ធិនេះត្រូវបានទទួលស្គាល់ដោយច្បាប់ជាតិ ក្នុងនោះ ផលប្រយោជន៍

[38] ច្បាប់ ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផល និងសេវា,មាត្រា៦,១៩-២១ និង http://www.wipo.int/wipolex/en/details.jsp?id=5783។
[39] ច្បាប់ស្តីពី ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលដែលមានប្រយោជន៍ និងគំរូឧស្សាហកម្ម, មាត្រា១។
[40] ច្បាប់ស្តីពី ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលដែលមានប្រយោជន៍ និងគំរូឧស្សាហកម្ម, មាត្រា៨។

សិទ្ធិអ្នកនិពន្ធចែកចេញជា ពីរប្រភេទធំៗគឺសិទ្ធិបេតិកភណ្ឌនិងសិទ្ធិសីលធម៌។[41] សិទ្ធិបេតិកភណ្ឌអ្នកនិពន្ធមានសិទ្ធិផ្តាច់មុខក្នុងការប្រកបអាជីវកម្ម ឬការទាញផលប្រយោជន៍ពីស្នាដៃតាមរយៈការផលិតឡើងវិញ ការបោះពុម្ពផ្សាយជាសាធារណៈ ឬការបង្កើតស្នាដៃបន្ត។[42] សិទ្ធិសីលធម៌ជាសិទ្ធិដែលនៅជាប់ជាមួយអ្នកនិពន្ធជានិរន្ត លើខ្លឹមសារទម្រង់ទាំងមូលនៃស្នាដៃ ឈ្មោះរបស់អ្នកនិពន្ធ សិទ្ធិនេះជាសិទ្ធិផ្ទាល់ខ្លួនរបស់អ្នកនិពន្ធដែលមិនអាចដកចេញពីអ្នកនិពន្ធឡើយ។[43]

សារៈប្រយោជន៍មួយដែលម្ចាស់ព័ត៌មានត្រូវយកចិត្តទុកដាក់ការពារព័ត៌មានសម្ងាត់ នៅពេលបង្កើតកិច្ចសន្យាការងារដំបូង ឬកិច្ចសន្យាអនុប្បទាន ឬ កិច្ចសន្យាអាជ្ញាប័ណ្ណ។ មុនចុះកិច្ចសន្យាជាមួយតតិយជនម្ចាស់ព័ត៌មានត្រូវពិចារណាទៅលើវិធានការការពារកម្មវត្ថុនៃកិច្ចសន្យា ពីព្រោះថាឱកាសនៃការបាត់បង់លក្ខណៈសម្ងាត់នៃព័ត៌មានអាចនឹងកើនឡើង អាស្រ័យតាមសមមាត្រនៃវិសាលភាពនៃ ការបើកចំហរព័ត៌មានឲ្យភាគីនៃកិច្ចសន្យា។ ដូច្នេះ ការចែង"ខ" រក្សាការសម្ងាត់ក្នុងកិច្ចសន្យា មានសារៈសំខាន់ណាស់ ចំពោះម្ចាស់ព័ត៌មាន។[44] ដើម្បីអនុញ្ញាតឲ្យម្ចាស់ព័ត៌មានអាចធ្វើអាជីវកម្ម ទាញផលចំណេញផ្នែកសេដ្ឋកិច្ចពីព័ត៌មានទាំងនោះបាន ព័ត៌មានទាំងនោះត្រូវតែជាព័ត៌មានដែលត្រូវបានប្រើប្រាស់ក្នុងវិស័យពាណិជ្ជកម្ម ក៏ដូចជាក្នុងវិស័យផលិតកម្ម នៃផលិតផលថ្មីនិងគ្រប់សកម្មភាពពាណិជ្ជកម្មផ្សេងៗទៀតរបស់សហគ្រាស។ លក្ខខណ្ឌតម្រូវនៃការប្រើប្រាស់ព័ត៌មាន ដែលមានលក្ខណៈសម្ងាត់ក្នុងវិស័យពាណិជ្ជកម្មនេះ មានសារៈសំខាន់ក្នុងការបង្ហាញឲ្យឃើញថា ព័ត៌មាននេះផ្តល់ផលប្រយោជន៍សេដ្ឋកិច្ចឲ្យសហគ្រាស។ ម្ចាស់ព័ត៌មានអាចទទួលបាននូវផលចំនេញពាណិជ្ជកម្មតាមរយៈការប្រើប្រាស់ ឬការធ្វើអាជីវកម្ម។ ក្នុងទីផ្សារប្រកួតប្រជែង ម្ចាស់ព័ត៌មានអាចទទួលបាននូវផលប្រយោជន៍ពាណិជ្ជកម្មច្រើន ជាងដៃគូរប្រកួតប្រជែងដែលពុំមាន ឬពុំដឹងពីការប្រើប្រាស់ ឬការធ្វើអាជីវកម្មលើព័ត៌មាននោះ ដោយសារលក្ខណៈសម្ងាត់របស់វា។ ក្នុងករណីនេះគេអនុវត្តទ្រឹស្តី "ចំនេញដើម្បីចំណូល" ។ តំលៃពាណិជ្ជកម្ម ជាកត្តាទីពីរដ៏សំខាន់បន្ទាប់ពីភាពសម្ងាត់នៃព័ត៌មានដើម្បីសន្មត់ថា ព័ត៌មានមួយជាការសម្ងាត់ពាណិជ្ជកម្មសម្រាប់សហគ្រាស។[45]

---

[41] ច្បាប់ស្តីពី សិទ្ធិអ្នកនិពន្ធ,មាត្រា១៨។

[42] ច្បាប់ស្តីពី សិទ្ធិអ្នកនិពន្ធ,មាត្រា២១។

[43] ច្បាប់ស្តីពី សិទ្ធិអ្នកនិពន្ធ,មាត្រា២៦។

[44] ក្រសួងពាណិជ្ជកម្ម កម្មសិទ្ធិបញ្ញា បោះពុម្ពដោយក្រសួងពាណិជ្ជ និង ធនាគារអភិវឌ្ឍន៍អាស៊ីឆ្នាំ២០០៨ ទំព័រ៧០។

[45] http://www.wto.org/english/res_e/booksp_e/analytic_index_e/trips_01_e.htm

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានសិក្សាស្រាវជ្រាវទៅលើ ប្រធានបទ ការចុះបញ្ជីកម្មសិទ្ធិបញ្ញានៅកម្ពុជា រួចមកគឺធ្វើឱ្យយល់កាន់តែច្បាស់នូវអត្ថប្រយោជន៍ដ៏វិសេសវិសាលផ្នែកកម្មសិទ្ធិបញ្ញា ព្រមទាំងមានតម្លៃដ៏ពិសេស សម្រាប់ពាណិជ្ជករ និងអ្នកប្រកបរបរផ្សេងៗទៀត រួមទាំងសហគ្រាសខ្នាតតូច និងមធ្យម ឱ្យកាន់តែមានលំនឹងបន្ថែមទៀត ។ និយាយជារួម ក្រុមហ៊ុន សហគ្រាសនានា ដែលបានចំណាយធនធាន និងពេលវេលាការពារទ្រព្យសម្បត្តិរបស់ខ្លួនក្នុងវិស័យកម្មសិទ្ធិបញ្ញា ក្នុងនោះអាចបង្កើន ការប្រកួតប្រជែងឱ្យកាន់តែមានភាពខ្លាំងក្លាដល់សាធារណៈជន បានដឹងអំពីផលប្រយោជន៍ជាច្រើនទាំងលើ ឆាកជាតិ និងអន្តរជាតិ។

ផលប្រយោជន៍នៃកិច្ចការពារកម្មសិទ្ធិបញ្ញាគឺ ទទួលបានផលប្រយោជន៍ជាច្រើន ក្នុងវិស័ពាណិជ្ជកម្ម និងឧស្សាហកម្មជាដើម ដែលកើតចេញពីគំនិតប្រាជ្ញារបស់មនុស្ស ដែលផលប្រយោជន៍ទាំងនោះមាន ការរបង្ការទប់ស្កាត់ការពីការលួចចម្លងស្នាដៃនានាឬធ្វើត្រាប់តាមផលិតផលរបស់គេ ជៀសវាងលើការចំណាយប្រាក់ខ្ជះខ្ជាយនានាលើការស្រាវជ្រាវ និងការផ្សព្វផ្សាយលើទីផ្សារ បង្កើតអត្តសញ្ញាណមួយដែលមានភាពច្បាស់លាស់ លើផលិតផល និងសេវាកម្ម តាមរយៈ ម៉ាក ពាណិជ្ជនាម ផ្តល់អាជ្ញាប័ណ្ណ ឬការផ្ទេរសិទ្ធិផ្សេងៗ ឬការផ្ទេរនូវបច្ចេកវិទ្យាឱ្យកាន់តែមានភាពរីកចំរើនជាលំដាប់ ដើម្បីជម្រុញវិស័យសេដ្ឋកិច្ចជាតិឱ្យមានការអភិវឌ្ឍ ជម្រុញ លើកទឹកចិត្តដល់អ្នកសិក្សាស្រាវជ្រាវ អ្នកនិពន្ធ ឱ្យខិតខំបង្កើតស្នាដៃនានាឱ្យបានច្រើនដើម្បីជាប្រយោជន៍ដល់ប្រទេសជាតិ អាចពង្រីកអាជីវកម្មលើ និងទទួលបានការការពារលើឆាកអន្តរជាតិ។

ទន្ទឹមនឹងមានភាពរីកចំរើន ទទួលបានផ្លែផ្កាពីការចុះបញ្ជីកម្មសិទ្ធិបញ្ញាក៏នៅមានបញ្ហាប្រឈមនានាមួយចំនួនផងដែរ។ ដែលបញ្ហាទាំងនោះមានដូចជាភាពលំបាកនៃនីតិវិធីចុះបញ្ជីកម្មសិទ្ធិច្រើនផ្សេងគ្នាព្រោះដោយសារមានក្រសួងច្រើន។ ការលំបាកក្នុងការប្តឹងផ្តល់ប្រសិនបើមានការ ការលួចចម្លងម៉ាក រំលោភសិទ្ធិអ្នកនិពន្ធ និងការលិចធ្លាយ ការសម្ងាត់ក្នុងវិស័យពាណិជ្ជកម្មជាដើម។ ការលំបាកព្រោះអ្នកបង្កើតស្នារដៃពុំទាន់យល់ដឹងអំពីសិទ្ធិលើកម្មសិទ្ធិពីការបង្កើតស្នារដៃរបស់ខ្លួន។

បញ្ហាប្រឈមទាំងនេះ អាចធ្វើឱ្យ មានភាពលំបាកផងដែរដល់ពាពាណិជ្ជករ ឬ អ្នកវិនិយោគទុន។ និងបញ្ហាសំខាន់មួយទៀតនោះគឺ អនុវត្តច្បាប់ឱ្យមានប្រសិទ្ធិភាពខ្ពស់ផ្នែកម្មសិទ្ធិបញ្ញាគឺ ចង់សំដៅទៅលើមន្ត្រីអនុវត្តច្បាប់គ្រប់ជាន់ថ្នាក់ ដែលមានតួនាទី ត្រួតពិនិត្យ លើផលិតផលដែលនាំចេញនាំចូលពីប្រទេសមួយទៅប្រទេសមួយទៀត នៅមានកង្វះខាតក្នុងការត្រួតពិនិត្យ ចាត់វិធានការលើជនទុច្ចរិត ដែលខួចបន្លំ ម៉ាក ពាណិជ្ជនាម តាមព្រំដែន និងតាមអាកាសចរណ៍ជាដើម។

# អនុសាសន៍

ទន្ទឹមនឹងទទួលបានផលប្រយោជន៍ ពីកិច្ចការពារផ្នែកម្មសិទ្ធិបញ្ញា យ៉ាងសន្ធឹកសន្ធាប់មក ទាំងពាណិជ្ជករ អ្នកវិនិយោគទុន ក្រុមហ៊ុន សហគ្រាស ខ្នាតតូច និងមធ្យម។ ក្នុងនាមជាអ្នកសិក្សាស្រាវជ្រាវទៅលើ ប្រធានបទ ខាងលើរួចមក ខ្ញុំបាទមានអនុសាសន៍មួយចំនួន សម្រាប់ជាស្មារតីជួយពង្រឹងឱ្យកាន់តែមានភាពរីចំរើនបន្ថែមទៀតក្នុងវិស័យពាណិជ្ជកម្មដូចជា៖

គួរតែបង្កើតឲ្យមានក្រសួងតែមួយដើម្បីធ្វើការចុះបញ្ជីលើកម្មសិទ្ធិបញ្ញាគ្រប់មុខទាំងអស់ដើម្បីកាត់បន្ថយការចំណាយពេលវេលាច្រើននិងមានភាពលំបាកដល់អ្នកបង្កើតស្នាដៃ។

គួរតែបង្កើតឲ្យមានតុលាការពិសេសមួយផ្នែកពាណិជ្ជកម្មក៏ដូចជាវិស័យកម្មសិទ្ធិបញ្ញាដើម្បីឲ្យមានជំនាញវិជ្ជាជីវៈពិតប្រាកដក្នុងការវិនិច្ឆ័យប្រកបដោយត្រឹមត្រូវស្របតាមស្តង់ដា និងគោលការណ៍នៃច្បាប់ជាតិនិងអន្តរជាតិ។

គួរតែមានកិច្ចប្រតិបត្តិការ ឬសហការណ៍គ្នា ពីប្រទេសមួយទៅប្រទេសមួយទៀតបន្ថែមទៀតក្នុងការលុបបំបាត់ ការលួចចម្លងស្នាដៃ និងផលិតផល ជាពិសេស ប្រទេសដែលជាសមាជិក អង្គការពាណិជ្ជកម្មពិភពលោក(WTO) និងអង្គការកម្មសិទ្ធិបញ្ញាពិភពលោក។

គប្បីជម្រុញឱ្យមាន ការបង្កើតលិខិតបទដ្ឋាននានាបន្ថែមទៀត សម្រាប់គ្រប់គ្រង វិស័យកម្មសិទ្ធិបញ្ញាឱ្យកាន់តែមានភាពល្អប្រសើរ តាមភាពរីកចំរើនរបស់សង្គមជាតិ។

មន្ត្រីអនុវត្តច្បាប់ គួរតែពង្រឹងការអនុវត្តច្បាប់ប្រកបដោយប្រសិទ្ធិភាព និងតម្លាភាព ជាពិសេសលុបបំបាត់ អំពើអសកម្មនានានៅកន្លែងការងារ និង លុបបំបាត់អំពើពុករលួយនៅតាមច្រកព្រំដែននានាដើម្បីអភិវឌ្ឍន៍ប្រទេសជាតិឱ្យមានគុណភាព ប្រសិទ្ធិ ស្ថេរភាពសម្រាប់សេដ្ឋកិច្ចជាតិទាំងមូលដើម្បីឆ្ពោះទៅរកសង្គមដែលមានលក្ខណៈការគោរពច្បាប់ និងប្រកបដោយវឌ្ឍនភាពជានិរន្តរ។

# គន្ថនិទ្ទេស


## I.ឯកសារច្បាប់

១. រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។
២.ច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០១។

៣.ច្បាប់ស្តីពី ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និង គំនូរឧស្សាហកម្ម ឆ្នាំ ២០០២។

៤.ច្បាប់ស្តីពី សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ឆ្នាំ២០០៣។

៥.ច្បាប់ស្តីពីការគ្រប់គ្រងពូជន៍ដំណាំនិងសិទ្ធិអ្នកបង្កាត់ពូជដំណាំ ឆ្នាំ២០០៨។

## II.ឯកសារជាសៀវភៅ

១. ឯកសារបណ្តុះបណ្តាល របស់ ក្រសួងពាណិជ្ជកម្ម ស្តីពី កម្មសិទ្ធិបញ្ញា បោះពុម្ពដោយធនាគារអភិវឌ្ឍន៍អាស៊ី។

២. សៀវភៅ នីតិកម្មសិទ្ធិបញ្ញា របស់សាស្ត្រាចារ្យ ង៉ែត វិបុល បោះពុម្ពឆ្នាំ២០១៣-២០១៤។

៣. សៀវភៅ នីតិកម្មសិទ្ធិបញ្ញាកម្ពុជា របស់សាស្ត្រាចារ្យ នី វិចិត្រ បោះពុម្ពឆ្នាំ២០១៣។

## III.ឯកសារយកចេញពីវិបសាយ

១. ក្រសួងពាណិជ្ជកម្ម:www. moc.gov.kh
២. ក្រសួងរ៉ែ និងថាមពល: www.mme.gov.kh
៣. ក្រសួង ឧស្សាហកម្ម និងសិប្បកម្ម: www.mih.gov.kh
៤. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ:www.mef.gov.kh
៥. ក្រសួង វប្បធម៌ និងវិចិត្រសិល្ប:www.mcfa.gov.kh។
៦. http://www.wipo.int/about-ip/en/
៧. http://www.infoentrepreneurs.org/en/guides/create-your-marketing-strategy/
៨. http://www.wipo.int/wipolex/en/details.jsp?id=5783.
៩. http://www.wto.org/english/res_e/booksp_e/analytic_index_e/trips_01_e.htm
១០. en.wikipedea.org/wiki/Trade name.

# ឧបសម្ព័ន្ធ